# ទស្សនាវដ្តី

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

*THE NGO FORUM ON CAMBODIA*

ឆ្នាំទី០៤ លេខទី០៥ ខែមករា ឆ្នាំ២០០៧












ទស្សនាវដ្តី

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

លេខ ០៩ ខែមីនា ឆ្នាំ២០០៧

## មាតិកា

ឥរិយាបថដីស្រែ ៤៤៤ ហិកតា និងច្រូតស្រូវ........................ទំព័រទី ១

សិក្ខាសាលាថ្នាក់ជាតិស្តីពីជំរើសផ្សេងៗដើម្បីសុវត្ថិភាពស្បៀង......ទំព័រទី ២

ការឈឺចាប់ និងការព្រួយបារម្ភចេះតែបន្ត.................................ទំព័រទី ៤

ទំនប់វារីអគ្គិសនីកំចាយជាក្តីបារម្ភថ្មីសំរាប់ប្រទេសកម្ពុជា.........ទំព័រទី ៥

វេទិកាយុវជនប្រកួតពិភាក្សាដេញដោល ស្តីពីបញ្ហាយេនឌ័រ និងសន្តិសុខស្បៀង........................ទំព័រទី ៧

ប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកល........................................ទំព័រទី ៨

សេចក្តីថ្លែងការណ៍រួមនៃបណ្តាញអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជា.................................ទំព័រទី ១០

បឹងកេងកងក្លាយជាទីក្រុងរណប....................................ទំព័រទី ១២

សេចក្តីថ្លែងការណ៍របស់សិក្ខាសាលាតំបន់ទន្លេមេគង្គ.........ទំព័រទី ១៤

**គណៈកម្មាធិការត្រួតពិនិត្យ**

-លោក **ឈិត សំអាត**

-លោក **ទី សន**

-លោក **ឯក ស៊ីជន**

-លោក **ឡុច សុខា**

## អារម្ភកថា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) មានវត្តមានដើម្បីចែករំលែកព័ត៌មាន ពិភាក្សា និងធ្វើការតស៊ូមតិលើបញ្ហាអទិភាពនានាដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍នៅកម្ពុជា។ NGO Forum ចង់ឃើញប្រទេសកម្ពុជាមានប្រជាពលរដ្ឋរបស់ខ្លួនដែលជ្រួតជ្រាបអំពីព័ត៌មានទាំងឡាយ ព្រមទាំងបានទទួលការផ្តល់អំណាចឱ្យចូលរួមក្នុងសង្គមស៊ីវិលដ៏ព្រចះព្រចង់ និងរឹងប៉ឹងមួយដើម្បីផ្តល់ផលប្រយោជន៍ដល់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា។ NGO Forum ជំរុញអង្គការសមាជិករបស់ខ្លួន និងអង្គការទាំងអស់ដទៃទៀតឱ្យធ្វើការរួមគ្នាដើម្បីនិយាយពាក្យជាធ្លុងមួយដ៏មានឥទ្ធិពលដើម្បីការពារប្រយោជន៍ និងសិទ្ធិរបស់ជនក្រីក្រ។ NGO Forum គឺជាអង្គការសមាជិកភាពមួយសំរាប់ទាំងអង្គការក្នុងស្រុកនិងអន្តរជាតិទាំងឡាយ។ ជោគជ័យរបស់ NGO Forum គឺពឹងផ្អែកទាំងស្រុងទៅលើការខិតខំរបស់អង្គការសមាជិក។ ទស្សនាវដ្តីនេះមានបំណងចងក្រងសមិទ្ធផលនានារបស់អង្គការសមាជិកទាំងឡាយក៏ដូចជា ដើម្បីផ្តល់ព័ត៌មានថែមទៀតទាក់ទិននឹង ***ការងារអភិវឌ្ឍន៍ បរិស្ថាន ដីធ្លី និងការចិញ្ចឹមជីវិត*** និង***បញ្ហាយេនឌ័រ*** ដល់អ្នកអានទូទៅដោយរាប់បញ្ចូលប្រជាពលរដ្ឋនៅក្នុងខេត្តដាច់ស្រយាលនានាផងដែរ។ ទស្សនាវដ្តីនេះមានគោលបំណងពិសេសក្នុងការៈ

- លើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការរវាងអង្គការសមាជិកទាំងអស់របស់ NGO Forum ។
- បង្កើនការយល់ដឹងដល់ពលរដ្ឋកម្ពុជា អំពីបញ្ហានានានៃការអភិវឌ្ឍន៍កំពុងតែកើតឡើងដែលអាចប៉ះពាល់ដល់ជីវភាពរបស់ពួកគេ។ និង
- លើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការបង្កើត និងការកែលំអគោលនយោបាយដែលអាចប៉ះពាល់ដល់ជីវភាពរបស់ពួកគេ ។

NGO Forum សូមស្វាគមន៍នូវការចូលរួមចំណែកផ្តល់អត្ថបទសំរាប់ទស្សនាវដ្តីនេះ និងសូមស្វាគមន៍រាល់មតិរិះគន់ដើម្បីកែលំអនានា។

## PREFACE

The NGO Forum exists for information sharing, debate and advocacy on priority issues affecting Cambodia's Development. The NGO Forum wants to see Cambodia will have a well-informed and empowered population participating in a strong and vibrant civil society, to the benefit of poor and vulnerable people in Cambodia. The NGO Forum approaches to all its member organizations and active not-member organizations for working together to collate a strong one voice for protecting the underlying benefits of the poor. The NGO Forum is a membership organization for local and international NGOs, which owes its success to the efforts of its members. In the future, this magazine intends to compile the achievements of member organizations as well as to provide more information regarding ***development***, ***environment***, ***land*** and ***livelihoods***, and ***gender*** issues to a broader audience, including to people in remote provinces. Specific objectives of the magazine are as follows:

- To encourage collaboration among the member organizations of the NGO Forum;
- To increase the awareness of Cambodian people about contemporary development issues which affect their lives; and
- To promote people's participation in policy developments and reforms that may affect their lives.

The NGO Forum on Cambodia welcomes contributive articles from member organizations and any constructive criticism for improvement.

# តវ៉ាយកដីស្រែ ៤៤៤ ហិកតា និងច្រូតស្រូវ

ប្រជាពលរដ្ឋចំនួន ២២០ គ្រួសារ នៅក្នុងភូមិចំនួន ១០ រួមមានភូមិប៉ោយក្បឿង ភូមិជើងវត្ត ភូមិកណ្តាល ភូមិប៉ុស្តិ៍ចាស់ ភូមិប៉ោយសំរោង ភូមិប៉ោយព្រីង ភូមិប៉ោយព្រីង ភូមិប៉ោយតាប៉ែន ភូមិស្រែះខាងកើត ភូមិស្រែះខាងលិច និងភូមិស្រែះគោកស្រុក នៃឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យមានទំនាស់ជាមួយជាមួយអ្នកមានអំណាចជាអតីតយោធារងខេត្តបន្ទាយមានជ័យរំលោភយកដីស្រែរបស់ពួកគាត់តាំងពីឆ្នាំ១៩៩៦ ដោយមានមេឃុំព្រះនេត្រព្រះចេញមុខមកហាមឃាត់មិនអោយប្រជាពលរដ្ឋធ្វើស្រែនៅលើដីចំនួន ៤៤៤ ហិកតា ។

តាមឯកសារបំភ្លឺរបស់លោក **ជួន ហាំ** អតីតមេឃុំ ព្រះនេត្រព្រះអោយដឹងថាដីទំនាស់នេះជាដីទំនេរនៅចន្លោះឆ្នាំ១៩៧៩ ដល់ ១៩៩៣ ជាដីតំបន់អសន្តិសុខក្រោមការគ្រប់គ្រងរបស់អតីតខ្មែរក្រហម ។ នៅឆ្នាំ១៩៩១ អាជ្ញាធរស្រុកបានប្រជុំមេឃុំទាំងអស់ដើម្បីដោះស្រាយដីលំនៅដ្ឋាន និងដីស្រែសំរាប់ប្រជាជនធ្វើមាតុភូមិនិវត្តន៍ពីព្រំដែនខ្មែរថៃមករស់នៅក្នុងស្រុកវិញក្នុងឆ្នាំ ១៩៩២ពេលនោះលោកអតីតមេឃុំក៏បានសំរេចយកទីតាំងដីនៅខាងត្បូងភ្នំស្រែះជាដីសង់លំនៅដ្ឋានសំរាប់អ្នកមាតុភូមិនិវត្តន៍ដោយយកដីវាលខាងកើតអូរតាជ្រាំសំរាប់បែងចែកអោយប្រជាពលរដ្ឋធ្វើស្រែ ។

លុះមកដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៣ លោកអតីតមេឃុំ និងលោកអតីតប្រធានការិយាល័យ ស្រុកព្រះនេត្រព្រះ ព្រមទាំងលោកមេភូមិទាំង ១៣ភូមិ និងពលរដ្ឋមាតុភូមិនិវត្តន៍ប្រមាណ៣ ៩៦ នាក់ ដែលជាមេគ្រួសារនីមួយៗបានចេញទៅវាលខាងកើតអូរតាជ្រាំដើម្បីវាស់វែងដីស្រែនៅតំបន់នោះបែងចែកអោយតំណាងគ្រួសារនីមួយៗក្នុងមួយគ្រួសារបាន ២ ហិចតា ។ នៅពេលទៅដល់វាលស្រែនោះ ហើយលោកអតីតមេឃុំ និងក្រុមការងារបំរុងចុះវាស់វែងដីតាមភូមិនីមួយៗហើយប្រជាពលរដ្ឋបានទាមទារអោយអតីតមេឃុំធ្វើការចាប់ឆ្នោតយកទីតាំងដីស្រែតាមភូមិ ។

នៅឆ្នាំ១៩៩៦ ស្រាប់តែមានលោក **ទុំង ធី** បានដឹកនាំកំលាំងទ័ពការពារចំនួន ៣០ នាក់ ប្រដាប់ដោយអាវុធបើកត្រាក់ទ័រប្រមាណ ៣ គ្រឿងទៅភ្ជួរដីស្រែដែលជាចំណែករបស់ប្រជាពលរដ្ឋមាតុភូមិនិវត្តន៍ទាំង ១០ ភូមិ ដោយពុំបានសុំឬប្រាប់អតីតមេឃុំមេភូមិនោះឡើយ ។ ឃើញដូច្នេះ អតីតមេឃុំក៏បានឱ្យឈ្មោះ **ឡុត សឿ** និង **ឡុត មុំ** ជាជីវពលនៅភូមិជើងវត្ត និង ៣ នាក់ ទៀតដោយមិនចាំឈ្មោះទៅហាមប្រាមដល់កំលាំងទ័ពដែលទៅភ្ជួរលើដីស្រែនោះ ។ នៅពេលដែលជីវពលនេះត្រលប់មកវិញបានរាយការណ៍ប្រាប់អតីតមេឃុំថាគេមិនឈប់ភ្ជួរទេគឺគេធ្វើស្រែដើម្បីចិញ្ចឹមទ័ពមួយរយៈសិន ។ លុះព្រឹកឡើង លោកអតីតមេឃុំ និងជីវពលម្នាក់បានជិះម៉ូតូទៅដល់ស្រែនោះបានឃើញគេកំពុងភ្ជួរដីស្រែទំនាស់នោះមែន តែអតីតមេឃុំមិនបានទៅហាមឃាត់ទេ ដោយខ្លាចក្រែងមានទំនាស់ធំដុំឈានដល់បាញ់ប្រហារគ្នា ។ ពួកគាត់ក៏ ត្រឡប់មកវិញដោយស្នើការសំរុះសំរួលនៅសាលាស្រុក ប៉ុន្តែគ្មានទទួលលទ្ធផលអ្វីទេ ។

នៅដើមឆ្នាំ២០០៦ នេះប្រជាពលរដ្ឋបាននាំគ្នាទៅព្រោះស្រូវនៅលើដីទំនាស់នោះរបួតដំណាំស្រូវបានលូតលាស់ក៏ភាគីរំលោភជាទាហានបានយកត្រាក់ទ័រទៅភ្ជួរលុបតែមិនបណ្តាលអោយខូចខាតទាំងស្រុងនោះទេ ។ លុះដល់រដូវច្រូតកាត់ប្រជាពលរដ្ឋនាំគ្នាទៅច្រូតតែត្រូវភាគីម្ខាងទៀតហាមឃាត់ក៏កើតមានការប្តឹងគ្នាដល់តុលាការតែគ្មានដំណោះស្រាយ ។ ទីបញ្ចប់ប្រជាពលរដ្ឋក៏សំរេចចិត្តនាំគ្នាទាំងចាស់ទាំងក្មេងមកទីក្រុងភ្នំពេញ សំណូមពរអោយនាយករដ្ឋមន្ត្រីជួយ ។

លោក **សុខ សារេត** អភិបាលរងខេត្តបន្ទាយមានជ័យបានអោយដឹងថាទំនាស់ដីនេះភាគីប្រជាពលរដ្ឋមានប័ណ្ណកម្មសិទ្ធិ ដូចនេះប្រជាពលរដ្ឋត្រូវប្តឹងទៅតុលាការតែប្រជាពលរដ្ឋគ្មានជំនឿលើតុលាការទេ ។ លោកអភិបាលខេត្តរងរូបនោះបានសំណូមពរអោយប្រជាពលរដ្ឋត្រលប់ទៅខេត្តវិញដើម្បីសំរបសំរួលរកដំណោះស្រាយតែប្រជាពលរដ្ឋនៅតែមិនព្រម ។

ជាតំណាងប្រជាពលរដ្ឋសុំអោយរាជរដ្ឋាភិបាលជាពិសេសអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើបញ្ហាដីធ្លីមេត្តាជួយអន្តរាគមន៍ដើម្បីយកដីចំនួន ៤៤៤ ហិកតា នោះមកអោយប្រជាពលរដ្ឋវិញព្រោះប្រជាពលរដ្ឋរស់នៅដោយពឹងផ្អែកទាំងស្រុងទៅលើដីស្រែតែប៉ុណ្ណោះ ។

អត្ថបទដោយក្រុមការងារដីធ្លីនៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា



# សិក្ខាសាលាថ្នាក់ជាតិស្តីពីជំរើសផ្សេងៗដើម្បីសុវត្ថិភាពស្បៀង

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៦ បណ្តាញកាត់បន្ថយថ្នាំកសិកម្ម ក្រោមការឧបត្ថម្ភរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum on Cambodia) បានរៀបចំសិក្ខាសាលាមួយដែលមានអ្នកចូលរួមសរុបចំនួន ៨៤ នាក់មានស្ត្រី ១៣ នាក់ដែលអញ្ជើញមកពីមន្ទីរពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល កសិករក្នុងខេត្ត តំណាងអង្គការ និងកសិករអញ្ជើញមកពីខេត្តនានា និងសមាជិកបណ្តាញ ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិ។ លោក **ស៊ាង ឈឿត** អនុប្រធានមន្ទីរកសិកម្មខេត្តបាត់ដំបងបានលើកឡើងថា ៣៥ ភាគរយនៃផ្ទៃដីសរុបជាផ្ទៃដីដាំដុះដំណាំកសិកម្មហើយមួយចំនួនតូចនៃផ្ទៃដីទាំងនេះ និងកំពុងប្រើប្រាស់សារធាតុគីមីដែលរួមមានជីគីមី និងថ្នាំកសិកម្មដែលជាមធ្យមជីគីមីប្រើអស់ចំនួនប្រហែល ៨៥០០ តោនក្នុមួយឆ្នាំ និងថ្នាំកសិកម្មប្រហែល ១០០.០០០ លីត្រ ក្នុងមួយឆ្នាំដែលកំពុងប្រើប្រាស់នៅលើដំណាំស្រូវ បន្លែ និងផ្លែឈើនៅក្នុងខេត្តបាត់ដំបងទាំងមូល។

លោក **ទី សន** អនុប្រធានវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ឡើងមានមតិស្វាគមន៍ដែលមានខ្លឹមសារដូចតទៅ: វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ជាអង្គការសមាជិកភាពដែលបច្ចុប្បន្នមានអង្គការជាតិ និងអន្តរជាតិចំនួន ៨១ ជាសមាជិកចូលរួមក្នុងគោលបំណងដើម្បីផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកដើម្បីធ្វើការតស៊ូមតិទៅលើការអភិវឌ្ឍន៍ទាំងឡាយណាដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ NGO Forum មានកម្មវិធីធំៗ ៣ ដូចជា: កម្មវិធី ដីធ្លី និងជីវភាព, កម្មវិធីបញ្ហា និងការអភិវឌ្ឍន៍ និងកម្មវិធីបរិស្ថាន (គំរោងកាត់បន្ថយថ្នាំកសិកម្ម និងកសិកម្មនិរន្តរភាព)។ លោកបានសង្កត់ធ្ងន់ទៀតថា សុវត្ថិភាពស្បៀងជាស្នូលនៃការអភិវឌ្ឍន៍ហើយការប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមីកសិកម្មមិនបានចូលរួមចំណែកនៅក្នុងការកាត់បន្ថយភាពក្រីក្រនោះទេតែវាបែជានាំមកនូវបន្ទុកដ៏ធ្ងន់ធ្ងរទៅវិញដូចជា:

១. សំលាប់សត្វមានប្រយោជន៍

២. កើនឡើងនូវកត្តាចង្រៃផ្សេងៗ

៣. សំលាប់ជីវសាស្ត្រក្នុងដី

៤. ធ្វើឱ្យដីរឹង និងបាត់បង់ជីជាតិ

៥. ប៉ះពាល់ដល់សុខមាលភាពមនុស្ស និងសត្វ

លោកបានបញ្ជាក់បន្ថែមទៀតថាយើងមានជំរើសជាច្រើនដូចជាការប្រើប្រាស់ឱ្យអស់នៅលទ្ធភាពនូវធនធានដែលមាននៅក្នុងសហគមន៍ ដើម្បីជំនួសឱ្យការប្រើប្រាស់សារធាតុគីមី ដោយងាកមកផ្សំ និងប្រើប្រាស់ជីកំប៉ុស្តិ៍គោក និងកំប៉ុស្តិ៍ទឹក ព្រមទាំងអនុវត្តន៍នូវប្រព័ន្ធកសិកម្មចំរុះដើម្បីសុវត្ថិភាពស្បៀង និងស្ថេរភាពស្បៀង ជាងនេះទៅទៀតគឺការអនុវត្តនូវប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ។

ឯកឧត្តម **សឿង ស៊ុតថង** អភិបាលរងខេត្តបាត់ដំបង បានថ្លែងសុន្ទរកថាបើកអង្គសិក្ខាសាលាដោយបានគូសបញ្ជាក់ថា: ការប្រើប្រាស់ថ្នាំ កសិកម្ម និងជីគីមីកសិកម្មរបស់កសិករជាការបាត់បង់រូបបីយ៍ប័ណ្ណជាតិមួយយ៉ាងធំ ជាងនេះទៅទៀតធ្វើឱ្យប៉ះពាល់ដល់សុខភាព មនុស្ស សត្វ តាមរយៈការប្រើប្រាស់ដោយផ្ទាល់ និងដោយប្រយោលគឺមានផលប៉ះពាល់ដូចគ្នា។ លោកបន្តទៀតថាសិក្ខាសាលាថ្ងៃនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ព្រោះរួមមានដំណើរទស្សនៈកិច្ចចុះទៅពិនិត្យមើលជាក់ស្តែងនៅស្រែ ចំការ កិច្ចពិភាក្សា និងសំនួរ ចំលើយ ដើម្បីជាការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក។ បច្ចុប្បន្ននេះវិស័យ ៣ ចំពោះមុខបាននិងកំពុងធ្វើឱ្យប្រទេសជាតិយើងមានដំណើរការទៅមុខមានដូចជា: វិស័យកសិកម្ម, វិស័យឧស្សាហកម្មកាត់ដេរ និងវិស័យទេសចរណ៍។ ជាចុងបញ្ចប់លោកបានអំពាវនាវដល់លោកមេឃុំក្រុមប្រឹក្សាឃុំ និងកសិករពេលត្រឡប់ទៅវិញធ្វើការផ្សព្វផ្សាយបន្តដើម្បីឱ្យកសិករបានយល់ដឹង និងចូលរួមអនុវត្តន៍កសិកម្មចំរុះដើម្បីធានាឱ្យបាននូវសុវត្ថិភាពស្បៀង និងការកាត់បន្ថយការប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមីក្នុងការដាំដុះ។



ឆ្លងតាមរយៈសិក្ខាសាលារយៈពេលពេញមួយថ្ងៃយើងទទួលបាននូវលទ្ធផលដូចខាងក្រោមៈ

## ១.លទ្ធផលពីដំណើរទស្សនៈកិច្ចសិក្សា

### ក.បទពិសោធន៍ដែលអ្នកចូលរួមទទួលបានពីក្រុមប្រព័ន្ធកសិកម្មចំរុះ

ត្រូវស្ទូងស្រូវជាជួរសំរាប់ឱ្យត្រីហែលដើម្បីពន្លឿនការលូតលាស់របស់ត្រី, ការរៀបចំប្រព័ន្ធកសិកម្មចម្រុះ (ការរៀបចំស្រះ, ការដាក់ ផ្សាំកូនត្រី, ការផ្តល់ចំណី (ផលិត និងបច្ចេកទេស), រៀបចំប៉ាហា (សំណាញ់), ដាំដំណាំរួមផ្សំ (ការពារបាក់ដី), ការរៀបចំប្រព័ន្ធស្រោចស្រពនៅ(ជុំវិញស្រែ) ។

### ខ.ក្រុមប្រព័ន្ធប្រពលវប្បកម្ម

បច្ចេកទេសដែលអ្នកចូលរួមអាចទទួលបានពីប្រព័ន្ធប្រពលវប្បកម្មដូចជាៈ ការជ្រើសរើសពូជយកពូជសុទ្ធល្អ, ការរៀបចំដី (ថ្នាលសំណាបៈ ភ្ជួរ-រាស់ពីរដងលើកជារង, ការសាបៈ លាងពូជជាមួយទឹកអំបិលចំនួន ១៥ នាទី ស្រង់លាងទឹកឱ្យស្អាតត្រាំ ២៤ ម៉ោងលាងទឹកមួយថ្ងៃ ៣ដង, ការរៀបចំថ្នាលសំណាបៈ ដាក់ជីកំប៉ុស្តិ៍ និងផេះអង្កាមលើថ្នាលទទឹង ១ ម៉ែត្របណ្តោយ ៤០ ម៉ែត្រ ប្រើពូជ ១ គីឡូក្រាមសំរាប់ដី ០,១ ហិកតា, អាយុ សំណាបៈ រយៈពេល ១២-១៥ថ្ងៃ, របៀបស្ទូង : ស្ទូងជាជួរ, ចន្លោះគុម្ព ២៥ សង់ទីម៉ែត្រ និង២៥ សង់ទីម៉ែត្រ, ស្ទូងចំនួន ១ ដើម, ការប្រើជីៈ ៤០០ គីឡូក្រាមក្នុងទំហំដី ០,១ ហិកតា ។

### គ.ក្រុមជីកំប៉ុស្តិ៍ទឹក និងជីកំប៉ុស្តិ៍គោក

បច្ចេកទេសដែលអ្នកចូលរួមអាចទទួលបានពីជីកំប៉ុស្តិ៍ទឹក និងគោកមានដូចជាៈ ធ្វើជី, បរិស្ថាននៅជុំវិញផ្ទះស្អាតបរិសុទ្ធ, រក្សាសុវត្ថិភាព ដីបានល្អ, កាត់បន្ថយការចំណាយនៅក្នុងគ្រួសារ, ប្រើប្រាស់ជីគីមីនាំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស និងសត្វ ។

## ២.អនុសាសន៍ និងសំណូមពររបស់អង្គសិក្ខាសាលា

- សិក្ខាកាមទាំងអស់សែលបានចូលរួមជួយធ្វើការផ្សព្វផ្សាយបន្តឱ្យដូចជាពាក្យបុរាណពោលថា "ក្អែកមួយ មួយជាក្អែកដប់" ទីបំផុតទទួលបានជោគជ័យ ។
- អនុវត្តន៍តាមចំណេះដឹងដែលទទួលបាន
- រៀនសូត្រ និងស្រាវជ្រាវបន្ថែមទៀត
- ចាប់ផ្តើម និងបន្តផ្សំជី និងធ្វើជីកំប៉ុស្តិ៍ទឹក-គោក
- ធ្វើប្រព័ន្ធប្រពលវប្បកម្ម ដំណាំស្រូវក្នុងប្រព័ន្ធចម្រុះ
- រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលឱ្យបានដល់ថ្នាក់ស្រុក ។

*អត្ថបទដោយកញ្ញា **ម៉ែន ទណ្ណារ៉ា** មន្ត្រីគំរោងកាត់បន្ថយថ្នាំកសិកម្ម និង កសិកម្មនិរន្តរភាព ។*



# ការល្អឹចាប់ និងការព្រួយបារម្ភ បេះតែបន្ត

ជាធម្មតាមនុស្សដែលកើតមករស់នៅអាស្រ័យពឹងផ្អែកទៅលើធនធានធម្មជាតិដែលមានពីទន្លេទាំងនោះ ប៉ុន្តែដោយសារភាពរអាក់រអួល និងការផ្លាស់ប្តូរនានាបានធ្វើអោយមានការពាក់ព័ន្ធច្រើនទៅលើជីវភាពរស់នៅរបស់ប្រជាជនគ្រប់មូលដ្ឋានទាំងអស់ ។ នេះក៏ដោយសារឥទ្ធិពលនៃការអភិវឌ្ឍន៍របស់ប្រទេសអ្នកមានលុយច្រើនដែលចង់អភិវឌ្ឍន៍ ។ ប៉ុន្តែគំរោងអភិវឌ្ឍន៍ទាំងនោះខ្វះការចូលរួមពីសហគមន៍ ដែលនាំអោយការសិក្សាពីផលប៉ះពាល់នោះមានការលំបាក និងមិនបានគ្រប់ដណ្តប់អោយបានទូលំទូលាយទៅលើផលប៉ះពាល់ទាំងនោះទេ ហើយបញ្ហាដែលបានលើកឡើងក្នុងការសិក្សានោះក៏មិនត្រូវបានធ្វើការសិក្សា និងដោះស្រាយអោយបានហ្មត់ចត់ល្អដែរ ។

បញ្ហាដែលបារម្ភធំបំផុត គឺការបង្កើតអោយមានទំនប់វារីអគ្គិសនី ហើយការផ្សព្វផ្សាយអំពីគំរោងនេះ អោយដល់ប្រជាជនពុំមានទាល់តែសោះ ពោលគឺគេចង់សិក្សាធ្វើអ្វី គឺគេធ្វើបែបនោះដោយពុំបានធ្វើការពិគ្រោះយោបល់ពីសហគមន៍ ហើយជាហេតុធ្វើអោយមានផលប៉ះពាល់ច្រើនដល់ប្រជាជនដែលរស់នៅតាមដងទន្លេទាំងនោះ (មានទន្លេសេសានជាដើម) ។ ប្រជាជនមានការព្រួយបារម្ភអំពីទំនប់ខ្នាតធំ ពីព្រោះសហគមន៍មួយចំនួនបានទទួលព័ត៌មានតាមរយៈ ទូរទស្សន៍ដែលបានបង្ហាញអោយ ឃើញពីផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនីខ្នាតធំដែលបានបាក់នៅចិន ហើយបានប៉ះពាល់យ៉ាងច្រើនទៅលើបរិស្ថាន និងសេដ្ឋកិច្ច សង្គម និងជីវិតប្រជាជនដែលរស់នៅតាមដងទន្លេទាំងនោះ ។ ប្រជាជនមានការព្រួយបារម្ភយ៉ាងច្រើនអំពីការបាក់ទំនប់នេះដោយមិនដឹងថាថ្ងៃណាមានបញ្ហាទាំងនេះដែរឬយ៉ាងណា?

ការព្រួយបារម្ភរបស់ប្រជាជននៅខាងក្រោមទំនប់នៅពេលមានភ្លៀងខ្លាំងម្តងៗប្រជាជនទាំងនោះមានការប្រុងប្រយ័ត្នយ៉ាងខ្លាំងពីការបាក់ទំនប់ខាងលើ ។ ពីព្រោះដោយសារពួកគាត់គ្មានជំរើសក្នុងការរត់គេចពីផលប៉ះពាល់ទាំងនោះ គឺមានតែរងចាំសេចក្តីស្លាប់ និងការខូចខាតធនធានរបស់ខ្លួនតែប៉ុណ្ណោះ នេះហើយជាការព្រួយបារម្ភយ៉ាងខ្លាំងសំរាប់ប្រជាជនក្រីក្រ និងទន់ខ្សោយ ។ ម្យ៉ាងទៀតក៏មានការភ័យខ្លាចអំពីគុណភាពទឹកមិនល្អផងដែរ ដែលប្រជាជនធ្លាប់មានបទពិសោធន៍ពីការបំពុលទឹកផងដែរ ជាក់ស្តែងមានកើតឡើងនូវជំងឺនានាដូចជារាករូសសើរស្បែកកមរមាស់ជាដើម ។ បន្ថែមពីលើនេះទៀតបញ្ហារឿងបន្លែ ត្រី សាច់សំរាប់ការចិញ្ចឹមជីវិតក៏កាន់តែមានការពិបាកក្នុងការស្វែងរក ។

### អារម្មណ៍របស់សហគមន៍នាពេលបច្ចុប្បន្ន...

ដោយសារតែពីពេលមុនប្រជាជននៅមិនទាន់យល់ដឹងអោយបានច្រើនអំពីបញ្ហាពីទំនប់ទាំងនេះ ប៉ុន្តែរហូតមកដល់ពេលនេះប្រជាជននៅក្នុងសហគមន៍មានចំណេះដឹងអំពីបញ្ហានេះបានខ្លះហើយ ហើយយើងសង្កេតឃើញថា ពួកគាត់មានឆន្ទៈខ្ពស់ណាស់ក្នុងការតស៊ូមតិលើបញ្ហាដែលជាអាយុជីវិតនេះ ។ ក្នុងនាមជាជនបង្គោល និងអ្នកតំណាងអោយសហគមន៍យើងមានយុទ្ធសាស្ត្រលើកទឹកចិត្តអោយសហគមន៍នៅតែបន្តប្តេជ្ញាតស៊ូមតិលើបញ្ហាទាំងនេះដោយបំផុសគំនិតអោយសហគមន៍ចេះសាមគ្គីគ្នា និងយល់អោយបានច្បាស់ពីគោលដៅ និងផលប្រយោជន៍យូរ អង្វែងសំរាប់ការតស៊ូមតិនេះ ។



គ្រប់ភូមិទាំងអស់មិនមានគ្រួសារណាដែលមិនព្រួយបារម្ភពីបញ្ហាទំនប់នេះទេ ។ លោកដឹងទេនៅដែលពួកយើងត្រលប់ទៅវិញប្រជាជននៅក្នុងសហគមន៍របស់យើងនឹងសួរនាំចង់ដឹងថាតើយើងធ្វើការងារតស៊ូមតិនេះដល់គឺរិតណាហើយ? ប្រជាជនតែងតែចូលរួមតាមដាន និងធ្វើការព្រួយបារម្ភជាមួយយើងជាប់ជាប្រចាំ ជាពិសេសគឺនៅពេលដែលមានគ្រោះធម្មជាតិនានាពីទំនប់នេះ ។ ទាល់តែមានដំណោះស្រាយសមស្របណាមួយដែលអាចទទួលយកបានទើបសហគមន៍សុខចិត្ត ។

### ពិភពលោកនេះនឹងមិនអង្គុយអោបដៃមើលអ្នករងគ្រោះដូចជាយើងនោះទេ

(នេះជាសំដីរបស់លោក **សែ ម៉ិនម៉ា** តំណាងសហគមន៍ស្រុកវើនសៃ)

ពេញចិត្តលះបង់ដើម្បីសហគមន៍ពីព្រោះបើយើងមិនការពារ និងជួយស្រែកពីបញ្ហានេះទេ នោះបញ្ហានេះ នឹងរឹតតែធ្ងន់ធ្ងរ និងខាតបង់ច្រើន ។ វាជាការចាំបាច់ណាស់សំរាប់រូបខ្ញុំ ដើម្បីសហគមន៍ទៅអនាគត ។ អ្វីដែលជាការលើកទឹកចិត្តអោយពួកយើងធ្វើការតស៊ូនៅក្នុងស្ថានភាពបែបនេះ គឺតស៊ូដើម្បីជីវិតរបស់យើង និងកូនចៅរបស់យើង ។ ដោយសារប្រជាជនស្ទើរតែទាំងអស់បានពឹងផ្អែកទៅលើធនធានធម្មជាតិតាមដងទន្លេទាំងនេះដែលជាអាយុជីវិតរបស់សហគមន៍ ។ ទឹកជាអាយុជីវិតរបស់យើងរាល់គ្នា !

*អត្ថបទដោយ លោក **សំ ចាន់ធី** មន្ត្រីគំរោងបរិស្ថាននៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

# ទំនប់វារីអគ្គិសនីកំចាយជាក្តីបារម្ភថ្មី សំរាប់ប្រទេសកម្ពុជា

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តំណាងដោយឯកឧត្តមរដ្ឋមន្ត្រី **ស៊ុយ សែម** និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី **គាត ឈុន** បានចុះហត្ថលេខាលើកិច្ចសន្យា ស្តីពីការវិនិយោគទុនលើគំរោងវារីអគ្គិសនីកំចាយ (Kamchay Hydroelectric BOT Project) របស់ក្រុមហ៊ុនចិនឈ្មោះ SINOHYDRO Corporation Limited នៅខេត្តកំពតនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០០៦ ដោយយោងតាមលិខិតសិទ្ធិប្រទានរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ១៦.សប្រទ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ដែលចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។ គំរោងវារីអគ្គិសនីកំចាយនេះមានរយៈពេល ៤៤ ឆ្នាំ រាប់ទាំងរយៈពេលសាសង់ ៤ ឆ្នាំ ផង។ គំរោងនេះនឹងគ្រោងចំណាយប្រមាណ ២៧០ លានដុល្លារ ហើយនឹងគ្រោងផ្តល់កំលាំងថាមពល ១៩៣ MW។ តំបន់ដែលក្រុមហ៊ុន SINOHYDRO Corporation Limited ធ្វើការអភិវឌ្ឍន៍វារីអគ្គិសនីនេះមានទីតាំងស្ថិតនៅចំងាយប្រមាណ ១៥ គីឡូម៉ែត្រភាគខាងជើងនៃទីរួមខេត្តកំពតដែលស្ថិតនៅក្នុងស្រុកកំពត។ ទីតាំងទំនប់ទី១ (ទំនប់អាងទី១) មានចំងាយប្រមាណ ៤.៥ គ.ម ពីលើតំបន់ទេសចរណ៍ធម្មជាតិទឹកឈូរ ហើយទំនប់ទី២ (ទំនប់អាងទី២) មានចំងាយប្រមាណ ៣០០ ម៉ែត្រ ពីលើតំបន់ទឹកឈូរ (របាយការណ៍ IESIA របស់ SAWAC ២០០៦)។

## ការព្រួយបារម្ភនានាចំពោះបរិស្ថាន ធនធានធម្មជាតិ និងបញ្ហាសង្គមផ្សេងៗ

- ប៉ះពាល់ដល់តំបន់ការពារមាត់ពាម (តំបន់ទឹកភ្លៀង) តំបន់ទ្រនាប់នៃតំបន់ការពារ និងតំបន់ពិសេស សំរាប់ការពារជីវៈចំរុះរបស់ឧទ្យានជាតិបូកគោ។
- បាត់បង់សម្បត្តិអកូឡូស៊ីដ៏មានតំលៃដោយសារការលិចលង់តំបន់កសិកម្ម ព្រៃឈើ ជំរកសត្វព្រៃ រំខានដល់ត្រីពង បង្កកំណើត និងឧបសគ្គដល់ផ្លូវបំលាស់ទីរបស់ត្រី (លិចលង់តំបន់ព្រៃឈើ ជំរកសត្វព្រៃមួយចំនួនក្នុងអាងទី១)។
- ការផ្លាស់ទីឬការតាំងលំនៅឡើងវិញរបស់ប្រជាជនដោយបង្ខំ (១៥-៣០គ្រួសារនៅក្នុង តំបន់អាងទី២)។
- ការថយចុះបរិស្ថានកើតចេញពីកំនើនការកាប់ព្រៃឈើដីឧទ្យានជាតិ។
- ការថយចុះទិន្នផលពីការចាប់ត្រីដោយការពន្លិចស្ទឹងទន្លេជ្រៅវែង និងទាក់ទងនឹងការលិចលង់ប្រឡាយ ហើយជាលទ្ធផលរំខានឬជាឧបសគ្គដល់ការបង្កកំណើត និងការបង្កើតកូនរបស់ត្រី។
- កំនើនឧប្បត្តិហេតុនៃជំងឺកើតពីទឹក ឬជំងឺទាក់ទងនឹងទឹក (អាចនឹងមានក្នុងអាងទី១ ដោយការពុករលួយនៃរុក្ខជាតិដែលជាជំរក និងកន្លែងបង្កកំណើតរបស់សត្វមូស ខ្យង់ខ្ចៅ និងសត្វល្អិតចង្រៃមួយចំនួនទៀត)។
- ថយចុះគុណភាពទឹកក្នុងអាង (អាចនឹងមានទូទៅនៅក្នុងអាងទីមួយនៅប៉ុន្មានឆ្នាំដំបូង)។
- ថយចុះឬផ្លាស់ប្តូរជលផលនៅខាងក្រោមអាងដោយសារបន្ថយលំហូរ និងជំនន់អតិបរមាព្រមទាំងបំរែបំរួលគុណភាពទឹក។
- បាត់បង់ប្រភេទត្រីដោយសារការបំលាស់ទីដោយសារការរារាំងបង្អាក់នៃទំនប់ទាំងពីរ (យោងតាមប្លង់គំរោងពុំឃើញមានកន្លែងអោយត្រីឆ្លងកាត់ពីខ្សែទឹកក្រោមទៅខ្សែទឹកខាងលើឡើយ។
- ភាពប្រែនៃដីទំនាបលិចទឹក និងទឹកប្រៃឡើងវាតរាលមាត់ពាម និងខ្សែទឹកខាងលើ (ដោយសាររំហួតទាបពេក)។
- ប៉ះពាល់ដល់ប្រពៃណី វប្បធម៌ ជំនឿ សាសនា និងទំលាប់ប្រពៃណីមូលដ្ឋានដែលមានស្រាប់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះធ្លាប់គោរពបូជា ដោយសារក្រុមហ៊ុននាំកម្មករមកពីតំបន់ផ្សេងៗចូលមករស់នៅលើទីតាំងនេះ។ ប៉ះពាល់ដល់កន្លែងសក្ការៈបូជាទាំងឡាយដូចជាព្រៃឬទីទួលអ្នកតា អារក្ស សំណាក់ម្ចាស់ទឹកដីក្នុងតំបន់។
- រំខានដល់សកម្មភាពទេសចរណ៍នៅក្នុងតំបន់ទឹកឈូរទាំងមូលដូចជាការរំខានដោយសារភាពចង្អៀតនៃចរាចរណ៍ការបំពុលខ្យល់ពីផ្សែង និងធូលី សំលេង និងរំញ័រ ការបំពុលទឹកឈូរ ធ្វើអោយកកល្អក់ និងសោភ័ណភាពមិនល្អចេញពីសកម្មភាពសាងសង់។ ផលប៉ះពាល់នេះនឹងធ្វើអោយមានការថយចុះនៃទេសរចជាតិ និងអន្តរជាតិ ហើយមានការខាតបង់ដល់របរលក់ដូររបស់ប្រជាពលរដ្ឋនៅមរណីយដ្ឋាន និងកន្លែងកំសាន្តក្នុងតំបន់ទឹកឈូរនេះព្រមទាំងថយចុះចំណូលទេសចររបស់ខេត្តកំពតមួយចំនួនដែរ។

ប្រភព: (របាយការណ៍ IESIA របស់ SAWAC ២០០៦)

## ការយល់ដឹងរបស់ប្រជាជនទៅលើផលប៉ះពាល់នៃទំនប់វារីអគ្គិសនី

ដោយសារមានការព្រួយបារម្ភរបស់សង្គមស៊ីវិលចំពោះគំរោងសាងសង់វារីអគ្គិសនីមួយដែលធ្វើនៅតំបន់ស្ទឹងកំចាយ ហេតុដូចនេះហើយទើបបានជាក្រុមសិក្សាស្រាវជ្រាវបានផ្តោតអារម្មណ៍យ៉ាងសំខាន់ទៅលើការសាងសង់នេះខេត្តកំពតដើម្បីសិក្សាអោយបានកាន់តែច្បាស់លើការយល់ដឹងរបស់ប្រជាពលរដ្ឋលើទំនប់វារីអគ្គិសនីនេះ។ តាមការសិក្សាបានបង្ហាញអោយឃើញថា ព័ត៌មាននានាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការសិក្សា និងការកសាងទំនប់នេះមិនត្រូវបានផ្តល់ដោយពេញលេញ និងជាផ្លូវការទៅអោយប្រជាពលរដ្ឋនៅតំបន់មូលដ្ឋាននោះដឹងជាមុនទេ។ មានក្រុមប្រឹក្សាឃុំ និងអាជ្ញាធរពាក់ព័ន្ធមួយចំនួនតូចប៉ុណ្ណោះដែលបានទទួលដំណឹងនេះតាមរយៈការជួបពិភាក្សានៅក្នុងដំណើរការសិក្សាអំពីគំរោងនេះរបស់ក្រុមហ៊ុនតែម្តងគត់។ ជាក់ស្តែងជាទូទៅការយល់ឃើញ ចំណេះដឹង និងបទពិសោធន៍អំពីទំនប់វារីអគ្គិសនីរបស់ប្រជាជន និងអាជ្ញាធរពាក់ព័ន្ធភាគច្រើននៅមានកំរិតតិចតួចណាស់ ជាពិសេសលើផលប៉ះពាល់នានាដែលអាចបណ្តាលមកពីទំនប់វារីអគ្គិសនីនេះ។ នេះជាបញ្ហាប្រឈមមុខមួយនាពេលបច្ចុប្បន្ននេះ និងជាពិសេសទៅថ្ងៃអនាគតនៅពេលដែលទំនប់នេះត្រូវបានកសាង និងដំណើរការ។ ប្រជាជនពុំបានត្រៀមខ្លួនអោយរួចជាស្រេចចំពោះផលវិបាកទាំងឡាយដែលកើតមានដល់ពួកគេនាពេលអនាគតដ៏ខ្លីនេះ។

## ការព្រួយបារម្ភណ៍របស់ប្រជាជន

- ការសាងសង់ទំនប់ស្ថិតនៅក្នុងរូបភាពផ្សេងទៀតដូចជាការជីកយករ៉ែ និងការរុករកធនធានធម្មជាតិផ្សេងៗទៀត
- ការបាក់ទំនប់ដែលបណ្តាលអោយបាត់បង់ដីធ្វើស្រែចំការ លិចលង់ផ្ទះសំបែង
- បាត់បង់ព្រៃឈើ
- បាត់បង់ប្រភពថាមពលពីធម្មជាតិ អុស និងធ្យូង
- គេហាមឃាត់មិនអោយឡើងភ្នំកាប់ឬស្សី បេះផ្លែឈើ
- បាត់បង់ការងារប្រចាំថ្ងៃ
- បាត់បង់ជំរកសត្វ
- ខ្វាចអត់មានទឹកប្រើប្រាស់

និយាយរួមប្រទេសកម្ពុជាពិតជាត្រូវការអភិវឌ្ឍន៍ដើម្បីការរីកចំរើនដូចបណ្តាប្រទេសនានាលើសកលលោក ។ ប៉ុន្តែទន្ទឹម និងមើលឃើញនូវផលប្រយោជន៍នៃការអភិវឌ្ឍន៍នេះ យើងក៏គួរតែគិតគូអោយបានល្អិតល្អន់ផងដែរទៅលើការការពារថែរក្សា និងការអភិរក្សនូវសម្បត្តិធនធានធម្មជាតិដែលជាឬសគល់នៃការអភិវឌ្ឍន៍ទាំងនេះ ។ រាជរដ្ឋាភិបាលជាពិសេសអ្នកអភិវឌ្ឍន៍ទាំងឡាយគួរតែយកចិត្តទុក និងគិតគូរអោយបានច្រើនទៅលើតុល្យភាពនៃផលចំណេញពីការអភិវឌ្ឍន៍ និងការខូចខាតបង់នានាដែលកើតមាន ។

*អត្ថបទដោយ លោក* ***សំ ចាន់ធី*** *មន្ត្រីគំរោងបរិស្ថាននៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*





# វេទិកាយុវជនប្រកួតពិភាក្សាដេញដោល ស្តីពីបញ្ហាយេនឌ័រ និង សន្តិសុខស្បៀង

កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៦ បណ្តាញវេទិកាយេនឌ័រនៃ NGO Forum on Cambodia បានសហការជាមួយក្រសួងកិច្ចការនារី រៀបចំវេទិកាយុវជនប្រកួតពិភាក្សាដេញដោលលើបញ្ហាយេនឌ័រ និងសន្តិសុខស្បៀង ក្រោមប្រធានបទពីរ គឺ: (១) ប្រាក់ចំនូល និងគ្រួសារទាក់ទិននឹងចំណាកស្រុក (២) សន្តិសុខស្បៀងលើស្ត្រីពឹងពាក់ទាំងស្រុងលើ ធនធានធម្មជាតិ។ វេទិកានេះបានរៀបចំឡើងនៅឯស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ដែលមានអ្នកចូលរួមចំនួន ១៥០ រូប រួមមាន មន្ត្រីក្រសួងកិច្ចការនារីចំនួន ២ រូប សមាជិកបណ្តាញវេទិកាយេនឌ័រចំនួន ៤៥ រូប លោកសាស្ត្រាចារ្យចំនួន ៣ រូប និងនិស្សិតចំនួន ១០០ រូប ដែលមកពីសាកលវិទ្យាល័យចំនួន ៤ គឺ សកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង សកលវិទ្យាល័យជាតិគ្រប់គ្រង សកលវិទ្យាល័យបញ្ញាសាស្ត្រ និង សកលវិទ្យាល័យភូមិន្ទភ្នំពេញ។

វេទិកាយុវជនប្រកួតពិភាក្សាវែកញែកនេះរៀបចំឡើងក្នុងគោលបំណងផ្តល់ជាឱកាសដល់យុវជន និងយុវនារីទាំងអស់បានជួបជុំ និងពិភាក្សាដេញដោលគ្នាដើម្បីបង្កើនការយល់ដឹងស្តីពីបញ្ហាយេនឌ័រ និងសន្តិសុខស្បៀងដែលមានការពាក់ព័ន្ធទៅនឹងប្រាក់ចំនូលគ្រួសារ និងបញ្ហារបស់ស្ត្រីដែលត្រូវរកប្រាក់ចំនូលដើម្បីអោយមានសន្តិសុខស្បៀងគ្រប់គ្រាន់ដោយត្រូវការពឹងពាក់ទាំងស្រុងលើធនធានធម្មជាតិ។ ទន្ទឹមនឹងនោះ អ្នកចូលរួមទាំងអស់ក៏កំនត់បាននូវចំនុចគន្លឹះសំខាន់ៗដូចជា ផលប្រយោជន៍ ផលប៉ះពាល់ ភាពប្រឈមបញ្ហា និងកត្តាគ្រោះថ្នាក់ផ្សេងៗតាមរយៈការធ្វើចំណាកស្រុក។ វេទិកាប្រកួតពិភាក្សានេះមិនមែនដើម្បីយកឈ្នះចាញ់នេះទេ គឺជាការពិភាក្សាដើម្បីស្វែងរកអំណះអំណាងល្អៗពីក្រុមគាំទ្រ និងក្រុមបដិសេធតែប៉ុណ្ណោះ។

នាបច្ចុប្បន្ន យេនឌ័រ និងសន្តិសុខស្បៀងគឺជាប្រធានបទមួយទាក់ទិនទៅនឹងយុទ្ធសាស្ត្រទី១ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៣ ហើយក៏ជាផ្នែកមួយដែលជ្រើសរើសចេញពីគោលដៅអភិវឌ្ឍន៍សហស្សវត្សដែលឆ្លើយតបទៅនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងលើនារីភេទ និងរួមគ្នាជាមួយផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំបន្ត ២០០៦-២០១០ ក្នុងការកាត់បន្ថយភាពក្រីក្រ ពិសេសនៅតំបន់ដាច់ស្រយាលដែលមានអង្គការជាតិ-អន្តរជាតិកំពុងតែដំណើការយ៉ាងស្រួចស្រាវផងដែរ។ ជាតួយ៉ាងប្រជាជនកម្ពុជាភាគច្រើនមានមុខរបរកសិកម្មអាស្រ័យលើទឹកភ្លៀងសំរាប់ផ្គត់ផ្គង់សន្តិសុខស្បៀងក្នុងគ្រួសារ ហើយនៅតំបន់ខ្លះមានការខ្វះស្រូវអង្ករហូបដែលធ្វើអោយគ្រួសារមួយចំនួនធំឈានទៅដល់ការជំពាក់បំនុល និងបណ្តាលអោយមានអសន្តិសុខស្បៀងជាប្រចាំ។ ក្រៅពីរបរកសិកម្មគ្រួសារនិមួយៗបានខិតខំស្វែងរកប្រាក់ចំនូលទៅតាមលទ្ធភាពរៀងៗខ្លួន និងភាគច្រើនគ្រួសាររស់នៅតាមជនបទត្រូវបង្ខំចិត្តធ្វើដំនើរមករកការងារធ្វើនៅទីប្រជុំជនទីក្រុងដើម្បីរកប្រាក់ចំនូលបន្ថែមមកផ្គត់ផ្គង់ជីវភាពគ្រួសារដែលជាតំរូវការចាំបាច់ដើម្បីធ្វើអោយស្ថានភាពសន្តិសុខស្បៀងក្នុងគ្រួសារប្រសើរឡើង។

នៅទីបញ្ចប់នៃដំណើរការប្រកួតពិភាក្សា ជ័យលាភីលេខ១ នៅវត្ថផ្ទាច់ព្រ័ត្របានទៅក្រុមនិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង និងជ័យលាភីលេខ២ បានទៅក្រុមនិស្សិតមកពីសកលវិទ្យាល័យបញ្ញាសាស្ត្រ ក្រោមការផ្តល់ពិន្ទុយ៉ាងសុក្រឹត្យពីគណៈកម្មការផ្តល់ពិន្ទុចំនួន ៤ រូប មាន លោកជំទាវ **កេត សំអាត** អគ្គនាយកក្រសួងកិច្ចការនារី លោកស្រីបណ្ឌិត **កង គ្រីស្លា** ព្រឹទ្ធសាស្ត្រាចារ្យសកលវិទ្យាល័យភូមិន្ទកសិកម្មចំការដូង លោកស្រី **អាង សុផា** មន្ត្រីស្រាវជ្រាវអង្គការ CCC និង លោកស្រី **ថ្វា សន្ថាន** មន្ត្រីគំរោងយេនឌ័រអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព។ វេទិកាយុវជនប្រកួតពិភាក្សាវែកញែកបានបញ្ចប់ទៅនឹងទទួលបានជោគជ័យគួជាទីមោទនភាពដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំពីសំណាក់អ្នកចូលរួមទាំងអស់ ជាពិសេស ប្អូនៗនិស្សិតបានធ្វើការតាមដានស្តាប់យ៉ាងយកចិត្តទុកដាក់បំផុត។

*អត្ថបទដោយ លោកស្រី **ធី សិលា** មន្ត្រីគំរោងយេនឌ័រនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*



# ប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកល

រាល់ផលិតផលដែលនាំចូលប្រទេសកម្ពុជាភាគច្រើនត្រូវបានបិទស្លាកសញ្ញាជាភាសាបរទេស។ យើងដឹងហើយថាសារធាតុគីមីមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាពមនុស្ស សត្វ រុក្ខជាតិ និងបរិស្ថាន បើទោះបីជាសារធាតុគីមីនោះវាមានសារៈសំខាន់យ៉ាងណាសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមក៏ពិតមែនតែវាបានផ្តល់នូវគុណវិបត្តមួយយ៉ាងធំផងដែរដូចជា ផលប៉ះពាល់ទៅលើសង្គម និងបរិស្ថាន តាមរយៈដំណើរការផលិត ការប្រើប្រាស់សារធាតុគីមី និងការបោះបង់ចោលនូវសំណល់គីមី និងសំណល់នៃផលិតផលដែលមាន ឬផ្សំពីគីមី។ ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ប្រកបដោយសុវត្ថិភាព និងទប់ស្កាត់ឱ្យបានពីការទទួលរងគ្រោះដោយអចេតនានូវសារធាតុគីមី ដូចនេះការផ្តល់នូវព័ត៌មានពីភាពគ្រោះថ្នាក់នៃសារធាតុគីមីទៅលើបុគ្គលិកកម្មករ សាធារណជន ត្រូវតែធ្វើឡើងជាចាំបាច់ហើយដែលចាត់ទុកថាជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតផងដែរ។ ដោយយល់ឃើញថាការជូនដំណឹង និងផ្តល់ចំណេះដឹងពីសារធាតុគីមីដល់បុគ្គលិក កម្មករ និងសង្គមស៊ីវិល គឺជាយុទ្ធសាស្ត្រដ៏មានសារៈសំខាន់និងមានប្រសិទ្ធភាពខ្ពស់ទើបប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកលត្រូវបានបង្កើតឡើងហើយវាជាផ្នែកមួយនៅក្នុងយុទ្ធសាស្ត្រជាដំណោះស្រាយសំរាប់គ្រប់គ្រងសារធាតុគីមីជាអន្តរជាតិនៅក្នុងកិច្ចប្រជុំកំពូលទីក្រុងរីយ៉ូក្នុងរបៀបវារៈទី ២១ ឆ្នាំ១៩៩២។ ទាក់ទងទៅនឹងការអនុវត្តន៍ប្រព័ន្ធខាងលើនេះអង្គការ UNITAR និង ILO ត្រូវបានជ្រើសតាំងជាអង្គការបង្គោលក្នុងការជួយគាំទ្រ និងជួយសម្របសម្រួលដល់បណ្តាប្រទេសទាំងអស់ដែលមានឆន្ទៈក្នុងការអនុវត្តន៍ប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកល ជាពិសេសការជួយគាំទ្រដល់កម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងការកសាងនូវសមត្ថភាពជំនាញ។

## ១.តើប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកលជាអ្វី?

ប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកល គឺជាបទដ្ឋានអន្តរជាតិសំរាប់ធ្វើការចាត់ថ្នាក់សារធាតុគីមី និងផ្តល់នូវព័ត៌មានពីគ្រោះថ្នាក់ និងភាពពុលរបស់សារធាតុគីមី។ ប្រព័ន្ធនេះត្រូវបានចាត់ទុកថាជាវិធានដែលមានលក្ខណៈជាអន្តរជាតិសំរាប់ធ្វើការចាត់ថ្នាក់សារធាតុគីមី ទោះតាមប្រភេទក្រុម និងភាពពុល ហើយជាវិធានក្នុងការផ្តល់ព័ត៌មានពីភាពគ្រោះថ្នាក់របស់សារធាតុគីមីវាជាប្រព័ន្ធថ្មីមួយដែលបង្កើតឡើងសំរាប់និតិវិធីនៃការចាត់ថ្នាក់សារធាតុគីមីទៅតាមៈ

**ក. លក្ខណៈរូបៈ** ឧទាហរណ៍ភាពអាចឆេះជាឧស្ម័ន ឬសារធាតុរាវ-រឹង និងអាចផ្ទុះ ភាពអាចកាត់ ឬ ច្រេះ និងការធ្វើអុកស៊ីតកម្មនៃប្រភេទសារធាតុរាវ ឬ រឹង។

**ខ. លក្ខណៈគ្រោះថ្នាក់ដល់សុខភាពៈ** ឧទាហរណ៍ភាពពុល ការធ្វើអោយរលាកស្បែក រលាកភ្នែក ឬការប៉ះពាល់ដ៏ធ្ងន់ធ្ងរទៅលើភ្នែក ការប៉ះពាល់លើប្រព័ន្ធបង្កកំណើត និងការបង្កជាជំងឺមហារីក។

**គ. ភាពពុលដល់បរិស្ថានៈ** ឧទាហរណ៍ភាពពុលទៅលើភាវរស់នៅក្នុងទឹក និងភាពពុលដល់ប្រព័ន្ធអេកូឡូស៊ី។

ប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកលត្រូវបានចាត់ទុកជាជំរើសមួយដែលមានលក្ខណៈសមហេតុសមផល និងទូលំទូលាយសំរាប់ៈ

- ជាវិធានដើម្បីកំណត់នូវលក្ខណៈ និងភាពគ្រោះថ្នាក់នៃសារធាតុគីមី
- អនុវត្តជានីតិវិធី និងប្រើប្រាស់ជាវិធានសំរាប់វាយតំលៃពីលក្ខណៈដែលបង្កនូវគ្រោះថ្នាក់របស់សារធាតុគីមីតាមរយៈការធ្វើចំណាត់ថ្នាក់ និងដាក់ស្លាកសញ្ញា។
- ជាវិធាននៃការជូនព័ត៌មានពីភាពពុល និងភាពគ្រោះថ្នាក់តាមរយៈការពិនិត្យលើស្លាកសញ្ញា និងការប្រើប្រាស់ឯកសារព័ត៌មានសុវត្ថិភាព។

## ២.ហេតុអ្វីបានជាត្រូវបង្កើតនូវប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកល?

ប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកលត្រូវបានបង្កើតឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោមៈ

ក. ដើម្បីលើកកំពស់កិច្ចការពារសុខុមាលភាពមនុស្ស និងបរិស្ថាន។

ខ. ដើម្បីផ្តល់នូវគ្រោងការណ៍ការងារសំរាប់រៀបចំប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីដល់ប្រទេសដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងសារធាតុគីមីពីមុនមក។

គ. ដើម្បីកាត់បន្ថយនូវការពិសោធន៍ និងការវាយតំលៃសារធាតុគីមីដោយគ្មានមូលដ្ឋាន។

ឃ. ដើម្បីសំរួលដល់ការធ្វើពាណិជ្ជកម្មជាអន្តរជាតិលើសារធាតុ និងផលិតផលគីមី។

## ៣.តើប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកល ផ្តល់នូវសារៈប្រយោជន៍អ្វីខ្លះ?

ការអនុវត្តន៍ដ៏មានប្រសិទ្ធភាពនូវការផ្តល់ព័ត៌មានពីគ្រោះថ្នាក់នៃសារធាតុគីមីដោយពឹងផ្អែកទៅលើការប្រើប្រាស់នូវប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកល និងផ្តល់សារៈប្រយោជន៍ជាច្រើនដល់រដ្ឋាភិបាល បុគ្គលិកកម្មករ និងសាធារណជន។ ប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកលមានតំលៃអតិបរិមា ប្រសិនបើអាចទទួលយកមកអនុវត្ត និងធ្វើការបញ្ចូលឱ្យមាននៅក្នុងប្រព័ន្ធបទប្បញ្ញត្តិច្បាប់សំខាន់ៗ សំរាប់ផ្នែកនៃការជូនព័ត៌មានពីគ្រោះថ្នាក់ដែលបង្កដោយសារធាតុគីមី។

## ៤.ផលប្រយោជន៍ទទួលបានចំពោះកម្មករ និងសង្គមស៊ីវិល

ការអនុវត្តន៍នូវប្រព័ន្ធចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកលគឺបានធ្វើអោយប្រសើរឡើងនូវសុវត្ថិភាពកម្មករ និងសាធារណៈជនតាមរយៈការផ្តល់ព័ត៌មានសមស្រប និងងាយយល់ពីគ្រោះថ្នាក់ដែលបង្កដោយសារធាតុគីមិ និងការប្រតិបត្តិជាក់ស្តែងទៅតាមសុវត្ថិភាពនៃការគ្រប់គ្រង និងប្រើប្រាស់។

*ដកស្រង់ចេញពីសៀវភៅប្រព័ន្ធនៃការចាត់ថ្នាក់ និងដាក់ស្លាកសញ្ញាសារធាតុគីមីជាសកលរបស់ក្រសួងបរិស្ថាន ដោយកញ្ញា* ***ម៉ែន វណ្ណារី*** *មន្ត្រីគំរោងកាត់បន្ថយថ្នាំកសិកម្ម និងកសិកម្មនិរន្តរភាពនៃវេទិកានៃ អង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*

## និមិត្តសញ្ញាបង្ហាញពីភាពគ្រោះថ្នាក់នៃសារធាតុគីមី



**សូមប្រយ័ត្ន :**

អាចបង្កឱ្យគ្រោះថ្នាក់ប្រសិនបើលេបចូល និងចូលតាមផ្លូវដកដង្ហើម

(May be harmful if swallowed and enters airways)



**សូមប្រយ័ត្ន :**

អាចបង្កឱ្យមានភាពងងុយគេង វិលមុខ ឈឺក្បាល និងរលាកផ្លូវដង្ហើម

(May cause drowsiness, dizziness & respiratory irritation)



**សូមប្រយ័ត្ន :**

ជាសារធាតុ ឬល្បាយដែលអាចមានប្រតិកម្មខ្លួនឯង ឬជាពែរអុកស៊ីតសរីរាង្គ

(Self-reactive substances and mixtures and organic peroxides)

Responsible Care



acute toxicity (high lebel)



acute toxicity (low lebel)



Flammable



Corrosive



Chronic toxicity



Hazardous to the aquatic environment

# សេចក្តីថ្លែងការណ៍រួម
# នៃបណ្តាញអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជា
# នៅក្នុងយុទ្ធនាការគាំទ្រកសិផលធម្មជាតិក្នុងស្រុក

ក្នុងរយៈពេលប្រមាណពីរទសវត្សកន្លងមកនេះ កសិករកម្ពុជាយើងបានងាកទៅរកការប្រកបរបរកសិកម្មតាមតាមបែបគីមី តាមរយៈការប្រើប្រាស់ជីគីមី ថ្នាំពុលគីមី និងគ្រាប់ពូជទំនើប។ កសិកម្មគីមីនេះបានជួយអោយទិន្នផលរបស់កសិករយើងកើនឡើង ប៉ុន្តែមិនធានាអោយមាននិរន្តរភាពទេ គឺវាកើនឡើងតែក្នុងរយៈខ្លីប៉ុណ្ណោះ ហើយវានាំមកនូវបញ្ហាជាច្រើននៅក្នុងរយៈពេលវែងដូចជា ផលប៉ះដល់សុខភាពទាំងកសិករ ទាំងអ្នកប្រើប្រាស់កសិផល ការកើនឡើងនូវចំណាយ និងថយចុះនូវប្រាក់ចំណូលរបស់កសិករ ការខូចខាតគុណភាពដី និងជីវសាស្ត្រចំរុះ ការបាត់បង់ពូជក្នុងស្រុក ។ល។

ដោយមើលឃើញបញ្ហាទាំងឡាយដែលបានរៀបរាប់ខាងលើនេះ បណ្តាញអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីជំរុញនូវការអនុវត្តន៍ប្រព័ន្ធកសិកម្មតាមបែបធម្មជាតិមួយដែលប្រសើរជាងកសិកម្មគីមី។ បណ្តាញអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជារបស់យើងនេះ បានទទួលនូវការចូលរួម និងសហការយ៉ាងជិតស្និទ្ធពីសំណាក់សមាគមន៍/សហគមន៍កសិករខ្មែរ និងទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អាជ្ញាធរមូលដ្ឋាន និងរាជរដ្ឋាភិបាល។

យើងបានរៀបចំយុទ្ធនាការស្វែងរកការ "គាំទ្រកសិផលធម្មជាតិក្នុងស្រុក" បីលើករួចមកហើយ ដែលលើកទីមួយប្រារពឡើងនូវខេត្តបាត់ដំបង លើកទីពីរនូវខេត្តតាកែវ និងលើកទីបីនេះ នៅខេត្តសៀមរាបចាប់ពីថ្ងៃ ២១-២៣ ខែធ្នូ ឆ្នាំ ២០០៦។

នៅក្នុងយុទ្ធនាការលើកនេះ ប្រធានបទជាច្រើនដែលទាក់ទងនឹងផលប៉ះពាល់នៃកសិកម្មគីមីការហូរចូលថ្នាំពុលជីគីមីសារធាតុគីមីដទៃទៀត និងអត្ថប្រយោជន៍នៃកសិកម្មតាមគោលការណ៍ធម្មជាតិត្រូវបានលើកយកមកជជែក និងពិភាក្សាយ៉ាងផុលផុស។ លើសពីនេះទៀត ការគំរាមកំហែងដល់ផលិតផលក្នុងស្រុក ដោយការហូរចូលនូវផលិផលពីបរទេស ក៏ត្រូវបានលើកយកមកជជែកពិភាក្សាដោយមានការវិភាគពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ទាំងថ្នាក់ទ្វេរភាគី ថ្នាក់តំបន់ និងថ្នាក់សកលលោក។

តាមរយៈការជជែកពិភាក្សាក្នុងយុទ្ធនាការលើកនេះយើងឃើញថា ការរប្រើប្រាស់ជី និងថ្នាំពុលគីមី ដ៏ច្រើនសន្ធឹកសន្ធាប់លើផលិតផលកសិកម្មនានា បានបង្កអោយមានផលអវិជ្ជមានជាច្រើនឥតគណនាលើ វិស័យសុខភាព បរិស្ថាន និងសេដ្ឋកិច្ចរបស់សង្គមយើងទាំងមូល។ ប្រជាកសិករខ្មែរដែលប្រើប្រាស់ជីគីមីសារធាតុបំប៉ន ថ្នាំពុលគីមី ថ្នាំ និងចំណីសត្វគីមីត្រូវបង្ខំចិត្តទៅខ្ចីប្រាក់ពីឈ្មួញឯកជន និងស្ថាប័នឥណទានមួយចំនួនដើម្បីផ្គត់ផ្គង់របរកសិកម្មរបស់គាត់ដើម្បីទទួលបានទិន្នផលប្រសើរជាង។ តែទោះជាយ៉ាងណាក៏ដោយ ក៏ជីវភាពរស់នៅរបស់ពួកគាត់មិនមានភាពប្រសើរឡើងឡើយ ផ្ទុយទៅវិញពួកគាត់ធ្លាក់ខ្លួនទៅក្នុងការជំពាក់បំណុល និងខិតខំប្រឹងប្រែងធ្វើការយ៉ាងលំបាកវេទនា ដើម្បីគ្រាន់តែសងបំណុលនោះវិញ។

លើសពីនេះទៀត ប្រទេសកម្ពុជាយើង នៅមានការខ្វះខាតយ៉ាងច្រើន ទាំងផ្នែកបច្ចេកវិជ្ជាធនធានមនុស្ស និងដើមទុន ក៏ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានចូលខ្លួនទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានាជាច្រើន។ កិច្ចព្រមព្រៀងទាំងនោះ ជាពិសេសការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក បានបង្ខំអោយផលិតផលក្នុងស្រុករបស់កម្ពុជា ត្រូវប្រកួតប្រជែងជាមួយផលលិតផលដែលហូរចូលមកពីបរទេស ដោយមិនមានការជួយអន្តរាគមន៍ណាមួយឡើយ ទោះបីនៅលើទីផ្សារក្នុងស្រុកក៏ដោយ។ កត្តាជាច្រើនដែលកសិករខ្មែរកំពុងតែប្រឈមមុខគឺការចំណាយខ្ពស់ទៅលើវត្ថុធាតុដើមកសិកម្ម ផលិតផលមិនត្រូវទៅតាមបទដ្ឋាន និងតំរូវការរបស់ទីផ្សារអន្តរជាតិ។ កសិករយើងនៅខ្វះការសហការណ៍គ្នាខ្វះព័ត៌មានអំពីទីផ្សារ ខ្វះបច្ចេកវិទ្យា និងខ្វះចំណេះដឹងផ្នែកបច្ចេកទេស ដែលកង្វះខាតទាំងនេះធ្វើអោយផលិតផលខ្មែរយើងមិនអាចឈានទៅប្រកួតប្រជែងលើទីផ្សារអន្តរជាតិបាន។ មិនតែប៉ុណ្ណោះ ផលិតផលខ្មែរថែមទាំងទទួលរងនូវការគំរាមកំហែងយ៉ាងធំធេងនៅលើទីផ្សារក្នុងស្រុក ដោយការហូរចូលយ៉ាងគគ្រឹកគគ្រេងនៃផលិតផលពីបរទេសជាពិសេសពីប្រទេសថៃ និងវៀតណាម។

ឆ្លងតាមលទ្ធផលនៃយុទ្ធនាការដែលបណ្តាញអភិវឌ្ឍន៍កសិកម្មធម្មជាតិកម្ពុជា យើងបានប្រារព្ធធ្វើឡើងកន្លងមក យើងឃើញថា ការលើកស្ទួយកសិផលធម្មជាតិក្នុងស្រុក ការអនុវត្តន៍កសិកម្មតាមបែបធម្មជាតិ កំពុងទទួលបានការគាំទ្រជាបណ្តើរៗ និងកាន់តែប្រសើរឡើងពីសំណាក់ប្រជាពលរដ្ឋគ្រប់កំរិត។ ផលិផលកសិកម្មធម្មជាតិក្នុងស្រុក ក៏ដូចជាផលិតផលខ្មែរទូទៅកំពុងតែទទួលបាននូវការគាំទ្រ និងកំពុងបង្កើនប្រជាប្រិយភាពរបស់ ខ្លួនកាន់តែប្រសើរឡើង។ យើងជឿជាក់ថាយុទ្ធនាការនេះ នឹងនៅតែបន្ត ហើយបង្កើនល្បឿនថែមទៀតនាពេលខាងមុខ ហើយនឹងនាំអោយមានការអនុវត្តន៍កសិកម្មតាមបែបធម្មជាតិ ដែលមិនប៉ះពាល់ដល់សុខភាព មិនបំផ្លាញ បរិស្ថាន និងអាចជួយអោយសេដ្ឋកិច្ចគ្រួសារ សហគមន៍ និងប្រទេសជាតិ មានការរីកចំរើនហើយធានាបាននូវនិរន្តរភាព។ ទន្ទឹមនឹងនេះ យន្តការកសិកម្មបែបធម្មជាតិនេះ ក៏បានជំរុញលើកទឹកចិត្តអោយមានការសហការគ្នារវាងកសិករ និងកសិករ ដើម្បីចងក្រងជាក្រុមសហគមន៍ ចែករំលែកពត៌មាន បទពិសោធន៍ ចំណេះដឹង និងបច្ចេកទេសដែលនឹងនាំទៅដល់ការប្រកួតប្រជែងបាននៅលើទីផ្សារទាំងក្នុងស្រុក និងអន្តរជាតិ។

បន្ថែមទៅលើយុទ្ធនាការដែលយើងបានធ្វើមកនេះ យើងសូមអំពាវនាវអោយមានការបន្តគាំទ្រអោយកាន់តែខ្លាំងឡើងថែមទៀតដើម្បីជំរុញការប្រើប្រាស់ផលិផលក្នុងស្រុក និងផលិតផលកសិកម្មធម្មជាតិដើម្បីលើកកំពស់ប្រជាប្រិយភាព ការគាំទ្រ និងការប្រើប្រាស់ផលិតផលខ្មែរយើងឈាន

ឆ្ពោះទៅកាន់សង្គមខ្មែរមួយ ដែលមាននិរន្តរភាពកសិកម្ម សុខមាលភាពល្អប្រសើរ និងកាត់បន្ថយបាននូវភាពក្រីក្រ។ ដើម្បីសំរេចបាននូវគោលបំណងខាងលើ យើងសូមលើកជាសំណូមពរមួយចំនួនដូចខាងក្រោម:

### សំរាប់កសិករ

- កាត់បន្ថយ និងឈានទៅរកការលុបបំបាត់ការអនុវត្តន៍កសិកម្មគីមី។
- បង្កើនការអនុវត្តន៍កសិកម្មតាមគោលការណ៍ធម្មជាតិ ដើម្បីទទួលបាននូវទិន្នផលកសិកម្ម ប្រាក់ចំណូលប្រចាំគ្រួសារដែលកាន់តែប្រសើរឡើង និងមាននិរន្តរភាពធនធានធម្មជាតិ។
- បង្កើនការស្រាវជ្រាវរកបច្ចេកទេសសមស្របថ្មីៗ ផ្សព្វផ្សាយចែករំលែកបទពិសោធន៍ និងពត៌មានគ្នាបង្កើនផលិតភាព និងគុណភាពដើម្បីទទួលបានសន្តិសុខស្បៀង និងឈានទៅការប្រកួតប្រជែងបាននៅលើទីផ្សារជាតិ និងអន្តរជាតិ។
- បង្កើនទំនាក់ទំនងចងក្រងសហគមន៍ និងបណ្តាញ ដើម្បីការពារផលប្រយោជន៍រួម រួមចំណែកអភិវឌ្ឍន៍សង្គមកម្ពុជាឈានទៅរកសង្គមកម្ពុជាមួយប្រកបដោយស្ថេរភាព និរន្តរភាព និងសេចក្តីរុងរឿង។

### សំរាប់អ្នកប្រើប្រាស់

- បង្កើនការគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុក ដែលជាកសិផលតាមបែបធម្មជាតិមិនប៉ះពាល់សុខភាពដើម្បីរួមចំណែកលើស្វ័យសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។
- រួមចំណែកកាត់បន្ថយភាពក្រីក្រក្នុងសង្គកម្ពុជា កសាងសង្គមកម្ពុជាដែលរុងរឿងប្រកបដោយស្ថេរភាព និរន្តរភាព និងការពារបរិស្ថាន ដោយការគាំទ្រ និងប្រើប្រាស់ផលិផលខ្មែរ ជាពិសេសកសិផលដែលផលិតឡើងតាមគោលការណ៍ធម្មជាតិ។
- ប្រើប្រាស់ និងគាំទ្រផលិតផលខ្មែរដោយផ្អែកលើពាក្យស្លោក "ប្រើប្រាស់ផលិតផលខ្មែរ ជួយបង្កើតការងារ សំរាប់ប្រជាពលរដ្ឋខ្មែរ" និង ប្រើប្រាស់ផលិតផលខ្មែររួមចំណែកអភិវឌ្ឍន៍ប្រទេសខ្មែរ។

### សំរាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

- ជំរុញលើកទឹកចិត្ត និងគាំទ្រ ប្រជាកសិករអោយអនុវត្តគោលការណ៍ និងបច្ចេកទេស កសិកម្មធម្មជាតិ សមស្រប អោយបានទូលំទូលាយទូទាំងប្រទេស។
- បង្កើនការគាំទ្រដល់សហគមន៍កសិករ ដើម្បីចងក្រងបង្កើតជាសហគមន៍ជាបណ្តាញ និងចូលរួមគាំទ្រការជ្រើសរើសពូជ ផលិតពូជ អភិរក្សពូជ និងដោះដូរមុខដំណាំផ្សេងៗ។
- ស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេស និងចំណេះដឹងថ្មី ដល់កសិករដើម្បីបង្កើនផលិតភាពកសិកម្មតាមបែបធម្មជាតិ។
- បណ្តុះបណ្តាលធនធានមនុស្ស សំរបសំរួលការផ្តល់ព័ត៌មានអំពីទីផ្សារ និងព័ត៌មាននានាដល់សហគមន៍កសិករ និងជួយស្វែងរកទីផ្សារសំរាប់ផលិតផលក្នុងស្រុក។
- បន្ត និងបង្កើនការផ្សព្វផ្សាយការអនុវត្តន៍កសិកម្មតាមបែបធម្មជាតិដល់កសិករ និងសហគមន៍កសិករ។

### សំរាប់ស្ថាប័នរាជរដ្ឋាភិបាល និងស្ថាប័នជាតិនានា

- គាំទ្រគោលនយោបាយទីផ្សារក្នុងស្រុកតាមរយៈការផ្សព្វផ្សាយ លើកកំពស់គុណភាព និងគុណប្រយោជន៍នៃផលិតផលកសិករខ្មែរ ដើម្បីអោយអតិថិជនទាំងក្នុង និងក្រៅស្រុកកាន់តែមានជំនឿជឿជាក់ថែមទៀត។
- អភិវឌ្ឍ និងគាំទ្រគោលនយោបាយថ្នាក់ជាតិ ស្តីអំពីការអភិវឌ្ឍន៍កសិកម្មធម្មជាតិទូទាំងប្រទេស ដើម្បី ធានាការអភិវឌ្ឍន៍របស់កសិករ លើវិស័យកសិកម្មប្រកបដោយចីរភាព និងស្ថេរភាពយូរអង្វែង។
- ជួយពង្រឹងសមត្ថភាព និងសិទ្ធិកសិករក្នុងការផលិតពូជ ដោះដូរពូជ អភិរក្សពូជ នៅតាមបណ្តា សហគមន៍ នូវពូជដំណាំ និងពូជស្រូវដែលមានស្រាប់។
- កសាង និងពង្រីកប្រព័ន្ធធារាសាស្ត្រអោយបានទូទាំងប្រទេស ដើម្បីធានាបានថាមានទឹកប្រើប្រាស់គ្រប់គ្រាន់ដើម្បីប្រកបរបរកសិកម្មទៀងទាត់ពេលវេលា និងមិនពឹងផ្អែកទៅលើទឹកភ្លៀង។
- ជួយដោះស្រាយ និងផ្តល់ដីធ្លីដល់ប្រជាកសិករ ជាពិសេសដីប្រកបរបរកសិកម្មប្រកបដោយយុត្តិធម៌ ដើម្បីអោយកសិករមានឱកាសបានប្រកបរបរចិញ្ចឹមជីវិតដោយសមស្រប។

# បឹងពោងពាយក្លាយជាទីក្រុងរណប

តំបន់បឹងពោងពាយស្ថិតនៅភាគពាយ័ព្យនៃទីក្រុងភ្នំពេញ ហើយមានចំងាយប្រហែល ០៥ គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ យើងចំណាយពេលប្រហែលជា ១៥ នាទី និងទៅដល់តំបន់នោះ ។ នៅតំបន់នោះមានប្រជាជនប្រមាណ ១១៨៥ គ្រួសារដែលរស់នៅយ៉ាងសុខសាន្តហើយពួកគេច្រើនប្រកបរបរជាអ្នកធ្វើស្រែចំការដាំដំណាំ និងលក់ឥវ៉ាន់កំប៉ិចកំប៉ុក ។ ពួកគាត់បានរស់នៅក្នុងតំបន់នេះតាំងពីឆ្នាំ១៩៧៩ រហូតដល់សព្វថ្ងៃ ក្នុងនោះមានគ្រួសារមួយចំនួនបានធ្វើសំណើសុំកាន់កាប់ដីធ្លីពីអាជ្ញាធរមូលដ្ឋានដូចដែលមាននៅក្នុងច្បាប់ភូមិបាលដែលបានដាក់អោយប្រើប្រាស់នៅឆ្នាំ២០០១ ។ លើសពីនេះទៅទៀតប្រជាពលរដ្ឋទាំងនេះ បានធ្វើសៀវភៅគ្រួសារ, អត្តសញ្ញាប័ត្រ, សៀវភៅស្នាក់នៅ និងប័ណ្ណបោះឆ្នោតព្រមទាំងប័ណ្ណកាន់កាប់ដីធ្លីដែលមានការទទួលស្គាល់ដល់អាជ្ញាធរខ័ណ្ឌឫស្សីកែវទៀតផង ។

នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៥ លិខិតលេខ.១០៩ *សជណ.ស* និងថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៦ លេខ. ៩៤ *សជណ.ស* សេចក្តីប្រកាសរបស់សាលាក្រុងស្តីពីការអភិវឌ្ឍន៍តំបន់នោះអោយក្លាយទៅជាតំបន់រណបដែលសហការវិនិយោគជាមួយក្រុមហ៊ុនកូរ៉េ (SASOKI EN) ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ លេខ ៤០៨ *សជណ.ស* សាលាក្រុងភ្នំពេញ និងសាលាខ័ណ្ឌឫស្សីកែវបានចេញលិខិតពង្រីកផ្លូវ៣០ម៉ែត្រ ដែលគិតពីចំនុចអ័ក្សទ្រូងផ្លូវដែលក្នុងនោះមានផ្លូវលេខ ១៩២៨ និង ផ្លូវ ៥៩៨ ដើម្បីអភិវឌ្ឍន៍តំបន់នោះ ។ ការពង្រីកផ្លូវនោះគឺពង្រីកគីពី ៧,៥ម៉ែត្រ ខាងជើង និង ២២,៥ ម៉ែត្រខាងត្បូង ។

ក្នុងខណៈនោះការប៉ាន់ស្មានតំលៃរបស់សាលាក្រុងដែលអាស្រ័យលើលក្ខណៈនៃដី, ផ្ទះ, សេដ្ឋកិច្ច លទ្ធផលនៃការប៉ាន់ស្មាននោះបើប្រៀបធៀបទៅនឹងតំលៃទីផ្សារជាក់ស្តែងនៅចន្លោះ $ ២០.០០-$ ៣០.០០ ក្នុង១ម៉ែត្រការេ ហើយការទូទាត់សំណងលើដីដែលទទួលការប៉ះពាល់ទាំងនោះមិនសមស្របទៅតាមតំលៃទីផ្សារនោះទេទាល់តែសោះ ។ រីឯការទូទាត់ សំណងដែលចេញដោយសាលាក្រុងមិនអាចអោយប្រជាជនយកទៅទិញដីសំរាប់រស់នៅ និងប្រកបមុខរបរជាក់ស្តែងកន្លែងផ្សេងបានទេ ។

គេទាំងអស់គ្នាមិនមានគំនិតប្រឆាំងនឹងការអភិវឌ្ឍន៍និងការការពង្រីកផ្លូវដើម្បីចូលទៅតំបន់បឹងពោងពាយនោះទេ ព្រោះនេះគឺបំរើជាប្រយោជន៍សាធារណៈ ប៉ុន្តែអ្វីដែលពួកគាត់ទាំងអស់គ្នាសង្ឃឹម និងចង់បាននោះគឺជាសំណងទូទាត់ដ៏សមរម្យទៅនឹងតំលៃលើទីផ្សារដែលយោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ នៃច្បាប់ភូមិបាល ។ ការពង្រីកផ្លូវនេះបានប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៤៩ គ្រួសារយ៉ាងខ្លាំង ហើយមិនបានទទួលសំណងអ្វីទាំងអស់ហើយគ្រួសារខ្លះទៀតបានទទួលសំណងទូទាត់យ៉ាងតិចតួចបំផុត ។ ដោយគ្រួសារខ្លះមានដីធំហើយសល់ដីនៅក្រោយតែចំណែកគ្រួសារខ្លះទៀតរងការប៉ះពាល់ដោយបាត់បង់ដីទាំងស្រុង ។

គួរអោយសោកស្តាយ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៧ប្រហែលជាម៉ោង ៧ ព្រឹកមានក្រុមប៉ូលីស និងទាហាន ជាច្រើនបានមកកុះរើ កំទេចរុះរើរបងផ្ទះ និង សំណង់របស់ប្រជាពលរដ្ឋដែលទទួលការប៉ះពាល់នោះ ។ ខណៈនោះមានសមាជិកបណ្តាញប្រព្រឹត្តិកម្មរុះរើតាំងទីលំនៅថ្មី (RAN) និង អង្គការ NGOs ២៩ ទៀតបានរួមគ្នាទប់ស្កាត់ការពារសិទ្ធិ និងធានាសិទ្ធិជូនប្រជាជន និងក្រុមគ្រួសារដែលទទួលរងគ្រោះខាងលើដោយសមរម្យ ។

ក្រុមបណ្តាញប្រព្រឹត្តិកម្មរុះរើតាំងទីលំនៅថ្មី (RAN) បានចាប់ផ្តើមប្រមូលទិន្នន័យ និងត្រួតពិនិត្យបញ្ហាដែលទាក់ទងទៅនឹងការបណ្តេញចេញដោយផ្អែកលើការប្រមូលទិន្នន័យ និងការត្រួតពិនិត្យមាន ៣០ គ្រួសារដែលទទួលការប៉ះពាល់នេះ ហើយការប៉ះពាល់នេះត្រូវបានចែកជាបីប្រភេទ ។

១. ១៩ គ្រួសារ ប៉ះពាល់លើលំនៅដ្ឋានទាំងស្រុង ។

២. ១៧ គ្រួសារ ប៉ះពាល់លើកន្លែងដែលពួកគាត់ប្រកបការងាររកស៊ី ។

៣. ១៣ គ្រួសារ ប៉ះពាល់តែបន្តិចបន្តួចដែលអាចរស់នៅបានទៀត ។

ប្រជាពលរដ្ឋ ២៤គ្រួសារ ដែលទទួលនូវសំណងទូទាត់យ៉ាងអយុត្តិធម៌ និង ៧ គ្រួសារទៀតត្រូវសម្រុកទីកន្លែកដោយគ្មានសំណងទូទាត់ ពីព្រោះវាជាអំពើដ៏អាក្រក់មួយនៃការអភិវឌ្ឍន៍ ។ អ្នកមីង **នាង ផា** អាយុ ៤៦ ឆ្នាំ ជាអ្នកធ្វើនំលក់ ហើយមានសមាជិក ៩ នាក់ក្នុងគ្រួសារ មានដី១៣,២៨ម៉ែត្រ គុណនឹង ១២,៩ ម៉ែត្រ បានប្រាប់យើងថា រដ្ឋាភិបាលយើងជាញឹកញាប់បានបង្ខំអោយគាត់ចុះហត្ថលេខាព្រមទទួលយកនូវសំណងទូទាត់ពីសាលាក្រុង ។ គាត់និយាយទៀតថា ប្រសិនបើគាត់ព្រមទទួលយកនូវសំណងទូទាត់ដ៏តិចតួចនេះគាត់, កូនប្រុស និងកូនស្រីរបស់គាត់នឹងក្លាយខ្លួនជាអ្នកសុំទាន ហើយប្រហែលជារស់នៅលើចិញ្ចើមផ្លូវ ឬអាចមានជីវិតរស់នៅដូចប្រជាពលរដ្ឋនៅតំបន់ដីក្រហម និងសំបុកចាបអញ្ចឹង ដែលកំពុងរស់នៅដោយគ្មានទឹកស្អាតប្រើប្រាស់សាលារៀន មន្ទីពេទ្យ និងគ្មានមុខរបរអ្វីទេ ព្រោះទីនោះនៅឆ្ងាយពុំមានកន្លែងរកស៊ីមុខរបតូចតាចដូចគាត់នេះបានទេ ។

បណ្តាញប្រព្រឹត្តិកម្មរុះរើតាំងទីលំនៅថ្មី (RAN) ជាជំនួយការរបស់គ្រួសារប្រជាពលរដ្ឋដែលរងការប៉ះពាល់ដូចជា ធ្វើការពិភាក្សាតាមរយៈវិទ្យុ និងផ្សព្វផ្សាយបន្តផ្ទាល់ និងផ្តល់ព័ត៌មានគ្រប់តំបន់ទាំងក្នុងស្រុក និងក្រៅស្រុក និងសំរបសំរួលសរសេរពាក្យបណ្តឹងតវ៉ាទៅអ្នកតំណាងរាស្ត្រទាំងអស់គ្រប់គណបក្សនយោបាយ *រដ្ឋសភា ព្រឹទ្ធសភា ក្រសួងដែនដីនគររូបនីយកម្ម* និងសំណង់ និងស្ថានទូតកូរេប្រចាំកម្ពុជា ហើយធ្វើសេចក្តីបញ្ជាក់ទៅសាលាក្រុង ហើយសុំធ្វើការចរចារលើបញ្ហាការទូទាត់សំណង ។

ក្រោយពីបានផ្តល់ការជួយសំរបសំរួលចំពោះរឿងនោះរួចមក យើងឃើញថាប្រជាពលរដ្ឋចំនួន ៣៥ គ្រួសារបានទទួលសំណងទូទាត់ពីសាលាក្រុងភ្នំពេញដែលមានការកើនឡើងពី ៤៥ ភាគរយ ដល់ ៨៥ ភាគរយ នៃតំលៃសំណងទូទាត់ដែលប្រជាពលរដ្ឋដែលរងផលប៉ះពាល់នោះបានទទួលគ្រប់ចំនួនយ៉ាងណាមិញ ក៏នៅមានចំនួន ២ គ្រួសារ លោក **អៀម ស្រ៊ីម** និង លោកស្រី **ជា ស៊ីណា** ដែលកំពុងធ្វើការដោះស្រាយបន្ត ។ បើយោងលើសេចក្តីប្រកាសជូនដំណឹងរបស់សាលាក្រុងភ្នំពេញ លេខ ៦៤ *រតក.សក្រ* ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៧ ឃើញថា សាលាក្រុងរាជធានីភ្នំពេញ ដែលក្រោមការដឹកនាំរបស់ឯកឧត្តម **កែប ជុតិមា** និង ធ្វើការដោះស្រាយជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ចំពោះការអភិវឌ្ឍន៍ទីក្រុងរណបនេះ អោយបានសមរម្យតាមប្រាក់គោលនយោបាយរបស់សាលាក្រុងភ្នំពេញ ។





# សេចក្ដីថ្លែងការណ៍ របស់សិក្ខាសាលាតំបន់ទន្លេមេគង្គ ស្ដីអំពី ចំការឈើដាំ នៅថ្ងៃទី ២១-២២ ខែវិច្ឆិកា ឆ្នាំ២០០៦

យើងទាំងអស់គ្នាមកពីប្រទេស ៥ ក្នុងតំបន់ទន្លេមេគង្គ និងមិត្តភ័ក្រពីប្រទេសនានាជាច្រើនទៀតបានជួបជុំគ្នាធ្វើសិក្ខាសាលានៅថ្ងៃទី ២១-២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ក្នុងខេត្តក្រចេះនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្លាស់ប្ដូរបទពិសោធន៍ និងរៀនសូត្រលើបញ្ហាចំការឈើដាំ និងផលប៉ះពាល់របស់វាលើជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់។

ក្នុងរយៈពេលសិក្ខាសាលានេះ យើងបានឮដោយផ្ទាល់ពីសហគមន៍នានា នៅក្នុងខេត្តមណ្ឌលគីរី ស្ទឹងត្រែង ក្រចេះ និងពោធិ៍សាត់អំពីផលប៉ះពាល់ដោយចំការឈើដាំដ៏ធំៗទៅលើការរស់នៅការចិញ្ចឹមជីវិត និងបរិស្ថានរបស់ពួកគេរៀងៗខ្លួន។ យើងក៏បានឮផងដែរអំពីផលប៉ះពាល់ដោយចំការឈើដាំតូចធំនានា ពីតំណាងនៃសហគមន៍នៅក្នុងប្រទេសកម្ពុជា ថៃ និងឡាវ ដែលទទួលរងនូវផលប៉ះពាល់ដោយចំការឈើដាំ។

យើងបានដឹងអំពីសារៈសំខាន់នៃព្រៃឈើសម្រាប់ជីវភាពរស់នៅ និងវប្បធម៌របស់សហគមន៍នានាដែលរស់នៅដោយអាស្រ័យពឹងពាក់ទៅលើព្រៃឈើដើម្បីជាម្ហូបអាហារ ថ្នាំសង្កូវ ប្រាក់ចំណូល និងការគោរពបូជា។ ចំការឈើដាំ មិនមែនជាព្រៃឈើឡើយ ។ នៅពេលដែលព្រៃឈើត្រូវបានបាត់បង់ដោយសារចំការឈើដាំពេលនោះជីវភាពរស់នៅរបស់សហគមន៍ជាច្រើនដែលរស់នៅក្នុង និងជុំវិញតំបន់ទាំងនោះក៏ត្រូវបាត់បង់ផងដែរ ។

យើងបានរកឃើញថា មានកត្តាកំណត់រួមជាច្រើនដែលចំការឈើដាំមានផលប៉ះពាល់លើជីវភាពរស់នៅរបស់សហគមន៍នានាទូទាំងតំបន់នោះ និងតំបន់ផ្សេងៗទៀត ។ ជាក់ស្ដែង :

១. ក្រុមហ៊ុននានា ដែលទទួលបាននូវព្រៃ និងដីសម្បទានសម្រាប់ចំការឈើដាំ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយស្ថាប័នរដ្ឋាភិបាលជាច្រើនលំដាប់ថ្នាក់។

២. ចំការឈើដាំបានកាត់បន្ថយបរិមាណដីយ៉ាងច្រើនសម្រាប់សហគមន៍ជនបទដើម្បីប្រកបរបរកសិកម្ម។ សម្បទានចំការឈើដាំជាច្រើនអនុញ្ញាតអោយក្រុមហ៊ុនយកដីដែលមានជីជាតិពីអ្នកភូមិ ហើយបានប្រែក្លាយទៅជាដំណាំឯកវប្បកម្ម។ បញ្ហានេះមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរក្នុងតំបន់ទាំងនោះដែលរួមមានការធ្វើអោយបាត់បង់ជីវចំរុះ ការធ្វើអោយដីរិកិរិលការបង្កើននូវភាពហួតហែង និងការបំពុលប្រភព ទឹកក្នុងតំបន់។

៣. ច្បាប់នានាដែលមានក្នុងពេលបច្ចុប្បន្នហាក់ដូចជា បំរើអោយផលប្រយោជន៍ក្រុមហ៊ុនឯកជន និងវិនិយោគិនជាជាងបំរើអោយផលប្រយោជន៍របស់សហគមន៍ក្នុងតំបន់។ ក្នុងករណីជាច្រើនសម្បទានិកមិនបានគោរពតាមច្បាប់របស់ជាតិឡើយ ប៉ុន្តែពួកគេពុំដែលទទួលការស្ដីបន្ទោស ឬផាកពិន័យឡើយ ។

៤. ក្នុងករណីជាច្រើនមានភស្ដុតាងដែលបញ្ជាក់ថា សម្បទានិកកំពុងតែប្រព្រឹត្តល្មើសពីកិច្ចព្រមព្រៀង និងកំពុងតែបំពារបំពានទៅលើដីកម្មសិទ្ធរបស់អ្នកភូមិ ដីសមូហភាព ឬដីសាធារណៈ និងព្រៃឈើដែលធ្លាប់បានប្រើប្រាស់ដោយសហគមន៍នានា។ មិនមែនមានតែករណីប៉ុណ្ណេះទេ ដែលធ្វើ អោយប៉ះពាល់ដល់លទ្ធភាពនៃការបំពេញសេចក្ដីត្រូវការក្នុងពេលបច្ចុប្បន្នរបស់សហគមន៍ ប៉ុន្តែក៏ធ្វើអោយប៉ះពាល់ដល់ការរីកលូតលាស់របស់សហគមន៍ដោយសារតែពួកគេត្រូវបាត់បង់ដីធ្លីសំរាប់មនុស្សជំនាន់ក្រោយផងដែរ ។

៥. នៅពេលសហគមន៍ចាប់ផ្ដើមទាមទារសិទ្ធិរបស់ពួកគាត់ត្រូវទទួលរងនូវការគៀបសង្កត់ពីជំនាញ ប៉ូលិស  យោធា និងអាជ្ញាធរក្នុងតំបន់។

៦. ផ្ទុយពីការអះអាងរបស់រដ្ឋាភិបាលដែលថា ចំការឈើដាំបានចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជួយកាត់បន្ថយភាពក្រីក្រ តែចំការឈើដាំបានបង្កើនភាពក្រីក្រដោយសារការបាត់បង់ទីជំរក ការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ធនធានសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍ និងការទប់ស្កាត់ពួកគេមិនអោយប្រើប្រាស់ធនធានធម្មជាតិទាំងនោះ ។

៧. កិច្ចសន្យារបស់ក្រុមហ៊ុន និងរដ្ឋាភិបាលដែលថាប្រជាជនក្នុងតំបន់នឹងទទួលបាននូវការងារធ្វើក្នុងចំការឈើដាំ ផ្លូវថ្នល់ សាលារៀន មណ្ឌលសុខភាព និងភ្លើងអគ្គិសនី ហើយមានជីវភាពរស់នៅកាន់តែប្រសើរឡើង ត្រូវបានគេបំភ្លេចចោលទាំងស្រុង។ ពីដំបូងប្រជាជនមានជំនឿទៅលើក្រុមហ៊ុន និងរដ្ឋាភិបាល ប៉ុន្តែក្រោយមកពួកគេមានការខកចិត្ត។

៨. ចំការឈើដាំនេះបានបង្កើតឡើងនូវអំពើហឹង្សាជាច្រើន។ ជូនកាលអំពើហឹង្សាបានកើតឡើងជាចំហដូចជាមានការសំលាប់មនុស្ស ការចាប់មនុស្សដាក់គុក។ ក្នុងករណីខ្លះទៀត សហគមន៍ត្រូវទទួលរងនូវការគំរាមកំហែង និងបំភិតបំភ័យដើម្បីកុំអោយពួកគាត់ហ៊ានធ្វើសកម្មភាពតវ៉ា។ តាមពិតសកម្មភាពរំលោភយកដីពីអ្នកភូមិដោយក្រុមហ៊ុន គឺជាសកម្មភាពហឹង្សា។

៩. គ្រប់ករណីទាំងអស់មានតែការតស៊ូរបស់ប្រជាជនប៉ុណ្ណោះ ដែលអាចផ្លាស់ប្ដូរស្ថានភាពនេះបាន។ ការតស៊ូពុំមែនមានន័យជាអំពើហឹង្សាឡើយ ។ វាមានន័យថាជាវិធីផ្សេងៗដែលធ្វើអោយប្រជាជនក្នុងតំបន់ទទួលបានសុវត្ថិភាព និងធ្វើអោយគេគោរពនូវសិទ្ធិរបស់ខ្លួន។

១០.ការប្រើប្រាស់ច្បាប់មានសារៈសំខាន់ណាស់ ប៉ុន្តែច្បាប់តែឯងមិនអាចធានាបានថា សិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានគេគោរពឡើយ ។

១១.យុទ្ធសាស្ត្រនៃការតស៊ូរបស់ប្រជាពលរដ្ឋត្រូវតែកើតឡើងពីសហគមន៍ដែលទទួលរងនូវការគំរាមកំហែងហើយមិនមែនកើតឡើងពីអង្គការ មិនមែនរដ្ឋាភិបាល ឬក្រុមនានាផ្សេងទៀតពីខាងក្រៅឡើយ ។

១២.ដោយធ្វើការរួមគ្នាជាមួយនឹងសហគមន៍ផ្សេងៗទៀត និងរកអោយឃើញនូវគោលជំហរួមគ្នានានានោះ ប្រជាជននឹងអាចពង្រឹងបាននូវ មូលហេតុរបស់ខ្លួន ។

១៣.តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលគឺជួយគាំទ្រដល់សហគមន៍ក្នុងការតស៊ូប៉ុន្តែពួកគេមិនមែនធ្វើការតស៊ូជំនួសសហគមន៍ឡើយ ។ អ្នកដឹកនាំត្រូវចេញពីសហគមន៍ ។

លក្ខខ័ណ្ឌសង្គម នយោបាយ សេដ្ឋកិច្ច របស់ប្រទេសយើងនីមួយៗមានភាពខុសៗគ្នា ហេតុនេះយើងត្រូវរកវិធីដោយខ្លួនឯងរៀងខ្លួន ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលកើតឡើងដោយចំការឈើដាំទាំងនោះ ។ ជាមួយគ្នានេះដែរដោយផ្អែកលើបទពិសោធន៍ និងការចូលរួមមតិក្នុងថ្ងៃកន្លងទៅនេះ យើងអាចកំណត់បាននូវគោលការណ៍ដ៏សំខាន់នានាដូចខាងក្រោមនេះ :

១. អ្នកដែលយល់ដឹងយ៉ាងច្រើនអំពីព្រៃឈើ ដី និងផលប៉ះពាល់នានារបស់ចំការឈើដាំ គឺជាអ្នកភូមិដែលរស់នៅទីនោះ និងជុំវិញទីនោះ ។ យើងត្រូវតែស្តាប់ពួកគេ ។ អ្នកធ្វើសេចក្តីសម្រេចលើគោលនយោបាយទាំងឡាយត្រូវតែស្តាប់ពួកគេដែរ ។

២. សុវត្ថិភាពរបស់ប្រជាជនទាំងផ្លូវកាយ ផ្លូវចិត្ត សេដ្ឋកិច្ច វប្បធម៌ និងនយោបាយត្រូវតែ ទទួលបាននូវការការពារ ។

៣. ត្រូវផ្តល់ព័ត៌មាន និងអប់រំសហគមន៍អំពីច្បាប់ និងបទដ្ឋាននានាដែលពួកគេអាចប្រើប្រាស់ ដើម្បីការពារនូវសិទ្ធិដីធ្លី និងធនធានធម្មជាតិរបស់ខ្លួន ។

៤. ទ្រទ្រង់អោយសហគមន៍មានលទ្ធភាពបង្កើតបណ្តាញការងារ ផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ជាមួយសហគមន៍ដទៃទៀតដែលប្រឈមនឹងបញ្ហាស្រដៀងគ្នា ។

៥. ត្រូវសម្របសម្រួល និងផ្តល់ព័ត៌មានអំពីខ្លឹមសារនៃសម្បទានលើចំការឈើដាំ និងកិច្ចព្រមព្រៀងទាំងឡាយអំពីការដាំដុះដល់សហគមន៍ដែលទទួលរងការប៉ះពាល់ រដ្ឋអំណាចមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលដែលជួយទ្រទ្រង់ ។

៦. ជំរុញអោយសហគមន៍ និងអ្នកធ្វើការសម្រេចចិត្តរបស់រដ្ឋាភិបាលយល់ដឹងអំពីផលប៉ះពាល់អវិជ្ជមាននៃចំការឈើដាំ និងធ្វើកិច្ចសន្យានៃការដាំដុះ ។

៧. សហគមន៍ដែលទទួលរងនូវផលប៉ះពាល់ គួរតែផ្តល់ព័ត៌មានទាំងនោះទៅអ្នកភូមិដទៃទៀតអំពីក្រុមហ៊ុនកំពុងស្វះស្វែងរកដីសម្បទានក្នុង តំបន់របស់ខ្លួន ។

៨. ជួយទ្រទ្រង់ដល់សហគមន៍ដែលទទួលរងនូវផលប៉ះពាល់អោយរកយុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងអំពីចំការឈើដាំដែលមានលក្ខណៈសមស្របទៅនឹងលក្ខខ័ណ្ឌ និងស្ថានភាពជាក់លាក់របស់ខ្លួន ។

៩. ប្រឆាំងចំពោះការគំរាមកំហែងដល់សារព័ត៌មាន ដូចជាហាមប្រាមមិនអោយសារព័ត៌មានរាយការណ៍ពីស្ថានភាពពិតនៅក្នុងតំបន់ចំការឈើដាំ និងហេតុការណ៍នានាដែលកើតមានពិតប្រាកដនៅក្នុងសហគមន៍ ដែលទទួលរងនូវផលប៉ះពាល់ ។ សូមលើកទឹកចិត្តអោយសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយនានារាយការណ៍អោយបានសុក្រិតអំពីបញ្ហានានាដែលកើតឡើងដោយចំការឈើដាំ និងក្រុមហ៊ុននានា ។

១០.ជួយទ្រទ្រង់ និងលើកកំពស់សិទ្ធិរបស់អ្នកភូមិអោយចូលរួមក្នុងការរៀបចំគោលនយោបាយ ដែលពាក់ព័ន្ធដល់ដីព្រៃសម្បទាន ។

១១.ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (IFI) ភ្នាក់ងារផ្តល់ជំនួយទ្វេភាគី និងពហុភាគីដោយរួមទាំងភ្នាក់ងារ UN ផង មិនគួរជំរុញអោយមានចំការឈើដាំឡើយ ហើយគួរមានតម្លាភាពអំពីប្រភេទនៃយុទ្ធសាស្ត្រនានា ដែលគេជំរុញអោយរដ្ឋាភិបាលទទួលយក ។

១២.រាល់គំរោងអភិវឌ្ឍន៍នានា ពិសេសចំការឈើដាំគួរតែត្រូវធ្វើការសិក្សាលំអិតស្តីអំពីផលប៉ះពាល់បរិស្ថាន និងសង្គម ដោយអង្គការឯករាជ្យមួយមុននឹងផ្តល់តំបន់ទាំងនេះ សម្រាប់ធ្វើការអភិវឌ្ឍន៍ដើម្បីធានាបាននូវសុខមាលភាពសង្គម និងកិត្តិ៍ជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ ។

១៣.រាល់គំរោងអភិវឌ្ឍន៍នានាត្រូវបញ្ចូលកម្មវិធីសំណងដោយសមរម្យបំផុតដល់អ្នករងគ្រោះពីផលប៉ះពាល់អវិជ្ជមាន (ចំការឈើដាំ) ។

១៤.សូមអោយអង្គសិក្ខាសាលាទាំងមូល (អង្គការជាតិ និងអន្តរជាតិ) ជួយពាំនាំកង្វល់របស់បណ្តាប្រទេសនៅអាស៊ី ពិសេសប្រទេសកម្ពុជាពីបញ្ហាចំការឈើដាំរបស់ក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណពីរដ្ឋាភិបាល ។ សូមជួយផ្សព្វផ្សាយដល់មជ្ឈដ្ឋានអន្តរជាតិទាំងឡាយជា ពិសេសមជ្ឈដ្ឋាននានានៅអឺរ៉ុប និងម្ចាស់ជំនួយ ។

***ព័ត៌មានបន្ថែមសូមទំនាក់ទំនង:***

១-លោក **ឈិត សំអាត** នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពី កម្ពុជា

ទូរស័ព្ទលេខ:០១២ ៩២៨ ៥៨៥

២-លោក **ហាក់ សារ៉ុ** មន្ត្រីកម្មវិធីព្រៃឈើ អុកស្វាមអង់គ្លេស

ទូរស័ព្ទលេខ:០១២ ៩៧៥ ៧២៦




វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល  ស្តីពីកម្ពុជា

ការិយាល័យ ផ្ទះលេខ ៩-១១ ទួលទំពូង ១ ភ្នំពេញ

ទូរស័ព្ទលេខៈ ០២៣ ២១៤ ៤២៩

ទូរសារលេខៈ ០២៣ ៩៩៤ ០៦៣

E-mail: ngoforum@ngoforum.org.kh

Website: www.ngoforum.org.kh